# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៩ ថ្ងៃទី០១-២៩ខែកុម្ភៈ ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល

លេខ ៩២



## លោក អេមីលដេតម្ប អតីតអភិបាលព្រះសហគមន៍ ភូមិភាគភ្នំពេញ ទទួលមរណភាព

## សេចក្ដីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " ( Apologeticus, Chapter 50:Tertullian ) ។ បងប្អូនជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ផ៉ត្រសិរី អ្នករៀបចំសំណុំរឿង ( Postulator ) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្ដល់ព័ត៌មានបន្ថែមអំពី អ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ខ្លះ ។ល។ សូមផ្ដល់ឈ្មោះអ្នកដែលអាចផ្ដល់សក្ខីភាពបានជូនមកឲ្យខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

**Tel : 077 800 211 / 096 34 22 144** ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ Email: martyrscambodia@gmail.com

# រូបថតសកម្មភាពផ្សេងៗ



តំណាងអន្តរសាសនាចុះសួរសុខទុក្ខ និងចែកអំណោយជូនដល់ទណ្ឌិតនៅពន្ធនាគារ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ មករា ២០១៦។ រូបថតដោយ សម្ផស្ស



ក្រុមកុមារកាយឫទ្ធិទូទាំងប្រទេសរបស់ព្រះសហគមន៍កាតូលិកប្រមាណ.......បោះជំរំ។ រូបថតដោយ សុធីរិទ្ធ



លោកបូជាចារ្យតូតែត បាណៃណាល់ ចុះសួរសុខទុក្ខសិស្សសាលានៅតំបន់ទន្លេ។ រូបថតដោយ ប៊ុន រឿន



គណៈកម្មការការប្រកួតខ្លែងឯក ដឹកនាំក្រុមប្រកួតទៅកាន់ទីតាំងបង្ហោះស្ថិតក្នុងស្រុកត្រាំកក់ ខេត្តតាកែវ។ រូបថតដោយ សុវណ្ណា



បេក្ខជនចំនួន២៨ នាក់ទទួលពិធីត្រាស់ហៅឱឡារឹក នៅព្រះសហគមន៍កំពង់ចាមក្រុង កាលពីថ្ងៃទី១៤ កុម្ភៈ ២០១៦។ សហការី



បងស្រីឃឹម សុខា (រូបទី២ខាងឆ្វេង) ថ្វាយពាក្យសច្ចាលើកដំបូងក្នុងក្រុមបងស្រីព្រះមាលា និងបងស្រីឡុង ម៉ារីរី (រូបទី២ខាងស្ដាំ) ទទួលបេសកកម្មទៅទ្វីបអាហ្វ្រិក។ រូបថតដោយ សុវណ្ណា


CSC
Formation, Dailouge, Cooperation

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

**Tel/Fax : (855) 23 224 120**

**Email : csccambodia@gmail.com / Website : www.catholiccambodia.org**

**ចាងហ្វាង : លោក លី សុវណ្ណា**



សេចក្ដីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# សារសង្ខេបរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក្នុងរដូវអប់រំពិសេស

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូម បានចេញសារពិសេសដោយជំរុញឲ្យ គ្រិស្តបរិស័ទយកចិត្តទុកដាក់បីចំណុចនៅក្នុងរដូវអបរំពិសេស ឆ្នាំ២០១៦ ដែលសកម្មភាពទាំងបី នេះ គឺផ្តោតនឹងយកចិត្តទុកដាក់ដល់សេចក្តីមេត្តាករុណា។

តាមរយៈសារនៅក្នុងឱកាសនោះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានជំរុញឲ្យគ្រិស្តបរិស័ទ រិះគិតថា ព្រះនាងម៉ារី គឺជាគំរូរបស់ព្រះសហគមន៍កាតូលិក ដែលប្រកាសដំណឹងល្អ ដោយសារតែព្រះនាងបានទទួលដំណឹងល្អមុនគេ ។

នៅក្នុងអំឡុងពេលនោះសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បាន អញ្ជើញបងប្អូនគ្រិស្តបរិស័ទឲ្យខិតខំធ្វើឲ្យរដូវអប់រំពិសេស ក្នុងឆ្នាំមហាករុណាទិគុណនេះក្លាយទៅជារយៈពេលមួយដ៏សំខាន់សម្រាប់បងប្អូន លើកតម្កើងព្រះហឫទ័យមេត្តាកុរណា របស់ព្រះជាម្ចាស់និងបានទទួលបទពិសោធន៍អំពីព្រះហឫទ័យមេត្តាករុណាឲ្យខ្លាំងជាងពីមុន។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបញ្ជាក់ថា "ខ្ញុំបានរំឭកបងប្អូនឲ្យព្យាយាមស្តាប់បន្ទូលព្រះជាម្ចាស់ ដើម្បី គូសសង្កត់អតិភាពនៃការស្តាប់និងអធិដ្ឋាន ដូច្នេះហើយនៅក្នុងរដូវអប់រំពិសេសនេះ ខ្ញុំនឹងចាត់ សាសនទូតនៃព្រះហឫទ័យមេត្តាករុណា របស់ព្រះជាម្ចាស់ ឲ្យទៅធ្វើជាសញ្ញាសម្គាល់ដ៏ជាក់ស្តែង ដើម្បឲ្យមនុស្សលោកឃើញយ៉ាងច្បាស់ថា ព្រះជាម្ចាស់គង់នៅក្បែរគេ និង លើកលែងទោសឲ្យគេផង"។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តទៀតថា ព្រះនាងម៉ារីបានទទួលដំណឹងល្អ ដែលអគ្គទេវទូតបានថ្លែង ហើយបានបន្តលើកតម្កើងព្រះឫទ័យមេត្តាករុណា របស់ព្រះជាម្ចាស់ រហូតដល់បានក្លាយជា គំរូដ៏ពេញលក្ខណៈពីព្រះសហគមន៍។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានសង្កត់ធ្ងន់ថា សកម្មភាពនិងការប្រកាសដំណឹងល្អរបស់ព្រះនាងម៉ារី គឺជា គំរូដ៏សំខាន់នៅក្នុងទំនាក់ទំនងរវាងគូស្វាមី ភរិយា និង កូន និយាយឲ្យចំគឺគ្រួសារ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តថ្លែងទៀតថា ចំណុចមួយទៀតដែលគ្រិស្តបរិស័ទគួរតែយកចិត្តទុកដាក់នោះដែរគឺ ទំនាក់ទំនងសម្ពន្ធមេត្រីរបស់ព្រះជាម្ចាស់និងមនុស្សលោក ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា សម្ពន្ធមេត្រីនេះគឺជា ប្រវត្តិសាស្រ្តនៃហឫទ័យមេត្តា ករុណរបស់ព្រះអង្គចំពោះមនុស្សលោក ។ នៅក្នុងចំណុចនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានលើកឡើងអំពីប្រវត្តិកំណើតរបស់ព្រះយេស៊ូ ដោយ ថ្លែងថា ព្រះយេស៊ូ គឺជា បុត្ររបស់ព្រះអង្គ ដែលតំណាងឲ្យព្រះហឫទ័យមេត្តាករុណាដ៏លើសលុប និង តំណាងឲ្យ សេចក្តីសុច្ចរិតដោយយកសេចក្តីពិតគឺជាមូលដ្ឋាន។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងទៀតថា ព្រះយេស៊ូជាស្វាមី ខណៈដែលព្រះសហគមន៍ជាមហេសី ហើយទាំងពីរបានសុខចិត្តធ្វើអ្វីៗដើម្បីគ្រិស្តបរិស័ទ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបញ្ជាក់ថា "ព្រះបុត្រារបស់ព្រះជាម្ចាស់ ពិតជាព្រះស្វាមី ដែលសុខចិត្តធ្វើអ្វីៗ ទាំងអស់ ដើម្បីឲ្យព្រះសហគមន៍ជាមហេសីបានស្រលាញ់ព្រះអង្គ ។ ព្រះអង្គភ្ជាប់នឹងព្រះសហគមន៍ដោយសេចក្តីស្រលាញ់ ដែលមិនដាក់លក្ខខណ្ឌអ្វីសោះ។ ព្រះអង្គសម្តែង ព្រះហឫទ័យ ស្រលាញ់នេះ ដោយរៀបអភិសេកនិងព្រះសហគមន៍អស់កល្បជានិច្ច "។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តទៀតថា ការដែលព្រះយេស៊ូបានសោយទីវង្គត ហើយមានព្រះជន្ម រស់ឡើងវិញគឺជារបៀបដែលព្រះជាម្ចាស់លោក បង្ហាញទៅបណ្តាអ្នកដែលប្រព្រឹត្តអំពើបាប ពោល អ្នកដែលធ្វើខុស ឲ្យនឹកសោកស្តាយចំពោះអំពើដែលខ្លួនបានធ្វើ ដើម្បីឲ្យគេអាចកែប្រែចិត្តគំនិត ជាថ្មី ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានពន្យល់គ្រីស្តបរិស័ទជាថ្មីទៀតថា ចំពោះពលីកម្ម ដែលព្រះយេស៊ូ ជាប់នៅលើឈើឆ្កាង គឺដើម្បីបង្ហាញអំពីការលះបង់ខ្លួនដើម្បីឲ្យព្រះសហគមន៍ដែលជាមហេសី និង គ្រិស្តបរិស័ទ ជាកូន កែប្រែចិត្តគំនិត រឹងរូស របស់ខ្លួន ។

ដោយឡែកចំណុចទីបីដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានសង្កត់ធ្ងន់នោះ គឺជំរុញឲ្យគ្រិស្តបរិស័ទយកចិត្តទុកដាក់នឹងការសម្តែងអំពីមេត្តាកុរណា ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ព្រះជាម្ចាស់គឺជំរុញឲ្យយើងម្នាក់ៗ ឲ្យមានចិត្តស្រ លាញ់អ្នកដ៏ទៃ និង ឲ្យយើងម្នាក់ៗធ្វើកិច្ចការនៃសេចក្តីមេត្តាករុណាទាំងខាងផ្លូវកាយ និង ខាងផ្លូវ ចិត្តចំពោះអ្នកដ៏ទៃ ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបញ្ជាក់ថា ៖ មេត្តាករុណាជាកិច្ចការប្រពៃណីរបស់ព្រះសហគមន៍ ហើយកិច្ចការទាំងនោះ រំឭកយើងជាគ្រិស្តបរិស័ទឲ្យយកចិត្តទុកដាក់លើកិច្ចការនេះ ដើម្បីជួយអ្នកដ៏ទៃ ទាំងខាងផ្លូវកាយ និងផ្លូវចិត្តផងដែរ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបន្តទៀតថា នេះគឺជាមធ្យោបាយសម្រាប់ដាស់តឿនគ្រិស្តបរិស័ទ ដែលតែងតែងោកងុយជាញឹកញាប់ ឲ្យចាប់អារម្មណ៍នឹងអ្នកក្រីក្រ និងឲ្យចូលកាន់តែជ្រៅទៅៗ ក្នុងស្នូល នៃ ដំណឹងល្អ ។ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបញ្ជាក់ថា សាច់របស់ព្រះគ្រីស្តគឺនៅក្នុងរូបរបស់អ្នកក្រីក្រ អ្នកដែលរងនូវទារុណកម្ម អ្នកដែលស្រេកឃ្លាន និងវង្វេង ហើយលើកទឹកចិត្តនឹងជំរុញឲ្យអ្នកដែលមានចិត្ត ធ្មើមធ្មៃ អ្នកមានអំណាច អ្នកមានស្តុកស្តម្ភ ឲ្យស្វែងយល់អំពីព្រះគ្រីស្ត ដែលត្រូវគេឆ្កាង ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានជំរុញឲ្យពួកគេយកចិត្តទុកដាក់ស្វែងយល់អំពីអត្ថន័យពិតនៃក្តីស្រលាញ់ និងចេះរំងាប់ការស្រេកឃ្លានចង់បានសុភមង្គល និងចង់បានសេចក្តីស្រលាញ់ ដែលមិនចេះអស់មិនចេះហើយ ។ នៅក្នុងឱកាសនោះ សារចុងក្រោយដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ សង្កត់ធ្ងន់ចំពោះគ្រិស្តបរិស័ទ នារដូវអប់រំពិសេសនេះគឺ "កុំចោលរដូវអប់រំពិសេស ... ព្រោះរដូវអប់រំពិសេសនេះ ពិតជាពេល វេលា សម្រាប់ប្រែចិត្តគំនិត "។

# កសិករបាត់បង់ជំនឿលើរដ្ឋ ដោយសាររឿងបញ្ហាតម្លៃស្រូវ



*កសិករកំពុងរោយស្រូវដែលទើបនឹងច្រូតបានក្នុងខែធ្នូនេះ ស្របនឹងថ្លៃស្រូវដែលកំពុងធ្លាក់យ៉ាងខ្លាំង។*

ពីមួយឆ្នាំទៅមួយឆ្នាំស្ថានភាព និងបញ្ហាដែលកសិករបានជួបប្រទះ ជុំវិញបញ្ហាតម្លៃស្រូវ និងអង្ករ គឺនៅតែដដែលគ្មានដំណោះស្រាយ។ នេះគឺជា សំដីរបស់បងប្អូនកសិករ ដែលកំពុងតែប្រមូលផលស្រូវ ។

លោក ពូលី សុខ ជាកសិករធ្វើស្រែមួយរូប ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឲ្យដឹងថា អារឿងតម្លៃស្រូវធ្លាក់ចុះនេះ វាមិនមែនជារឿងថ្មី របស់កសិករនោះទេ។ ឆ្នាំណាក៏ដូចឆ្នាំណាដែរ គឺវាកើតឡើងដដែលៗ នៅពេលដែលពួកលោកពូចាប់ផ្ដើមប្រមូលផលស្រូវ។

លោកបានបញ្ជាក់ថា "នេះមិនមែនជារឿងថ្មីទេ យើងជួបតែតចឹងរាល់តែឆ្នាំ ហើយឆ្នាំនេះយើងជួបទៀត" ។

លោកបានបន្តទៀតថា រហូតមកដល់ពេលនេះ ទាំងលោកពូ និងកសិករឯទៀតនៅក្នុងភូមិស្រុក នរណា ក៏អស់សង្ឃឹមដែរ ប៉ុន្តែវាមិនដឹងជារកអី គឺចេះតែខំធ្វើទៅ ដូច្នេះហើយបានជា ទាំងលោកពូ និងបងប្អូនអ្នកស្រុក ខំត្រដដើម្បីឲ្យកូនរៀន ហើយធ្វើយ៉ាងណាមិនចង់ឲ្យកូន ធ្វើអារបរធ្វើស្រែនេះបន្តទៀតទេ ។

លោកបានបន្តទៀតថា ពេលដែលស្រូវចាប់ផ្ដើមផើម គឺតម្លៃនៅគួរសមទេល្បាក់មួយគីឡូក្រាម ថ្លៃ ១.២០០រៀលទៅ១.៣០០រៀល អាស្រូវក្រអូប ហើយអាស្រូវអង្ករសរ អី គឺមួយគីឡូក្រាម គឺពី៨៥០ រៀលទៅ ជិត១.០០០ រៀលអីដែរ ប៉ុន្តែឲ្យតែពេលដែលយើងចាប់ផ្ដើមច្រូតប្រមូលផល គឺតាំងចាប់ផ្ដើមចុះ ស្រើតៗយកតែម្ដង ។

លោក រស់ ហាន ជាកសិករនៅក្នុងស្រុកភូមិជាមួយនឹងលោកពូ លី សុខដែរនោះ បាននិយាយដោយចម្ងល់ថា "ទាំងខ្ញុំនិងអ្នកភូមិឯទៀត គឺមិនយល់មិនដឹងពេលណាបានរដ្ឋាភិបាលលោកអាចជួយពួកយើងកើត"។

លោកបានបន្តទៀតថា សម្រាប់អ្នកដែលគេមានទុនច្រើនដូចជា រោងម៉ាស៊ីន គេអាចសាងសង់កន្លែងស្តុកធំៗ ដូច្នេះគេមិនចោទទេវាយ៉ាប់ តែយើងជាកសិករដែលធ្វើទៅហើយ ប្រញាប់ប្រមូលផលដើម្បី ដោះស្រាយនេះ ដោះស្រាយនោះ ភ្លាមៗ គឺយ៉ាប់រហូត។

លោកបានបញ្ជាក់ថា "ឥឡូវនេះឮថាតម្លៃស្រូវក្រអូបគឺខ្ញុំឮថា ធ្លាក់ដល់តម្លៃ ១.០៥០ទៅ ១.០៨០ រៀលអីទេ ហើយគេថា អាចនឹងធ្លាក់ចុះថែមទៀត ដល់ក្រោម១.០០០រៀល នៅក្នុងមួយគីឡូ ប៉ុន្តែខ្ញុំ គឺនៅសល់ប្រមាណជា ២ហិចតាទៀតមិនទាន់ច្រូត"។

លោកពូ លី សុខ បានឲ្យដឹងថា សម្រាប់អ្នកដែលមានធនធាន និងសំភារៈប្រើប្រាស់ខ្លួនឯង គឺមិនសូវជា ខាតបង់ទេ ប៉ុន្តែសម្រាប់អ្នកដែលខ្ចី បំណុលអង្គការ (ស្ថាប័នមីក្រូហិរញ្ញវត្ថុ) មកជួលគេមកចេញថ្លៃសាំង ថ្លៃច្រូត ជាពិសេស គឺថ្លៃបូមទឹកគឺយ៉ាប់។

លោកបានបញ្ជាក់ថា "ឆ្នាំនេះខ្សត់ទឹកទាំងខ្ញុំទាំងគេចំណាយច្រើនលើការជួលគេបូមទឹកដាក់ស្រែ"។ លោកបញ្ជាក់ទៀតថា "អ្នកមានម៉ាស៊ីនខ្លួនឯងអី គឺយ៉ាប់រឿងសាំង ដូចខ្ញុំចំណាយរាប់សិបម៉ឺនលើរឿងបូមទឹក តែបើអ្នកដែលគ្មានអត់មាន គឺរិតតែយ៉ាប់ដោយត្រូវគេអង្គុយរាប់ម៉ោងយកលុយៗ"។

រឿងបញ្ហាតម្លៃ ស្រូវធ្លាក់ចុះនេះ បុគ្គលិក នៅក្នុងក្រុមហ៊ុននាំចេញស្រូវ មួយដែលសុំមិនបញ្ចេញអត្តសញ្ញាណបានឲ្យដឹងថា រឿងវានៅតែដដែលទេ គឺរឿងអត់កន្លែងស្តុក រឿងដែលបណ្ដារោងម៉ាស៊ីនខ្វះទុន ប្រមូលទិញ ដូច្នេះដល់ពេលដែលបណ្ដារោងម៉ាស៊ីន ឈប់ប្រមូលទិញ គឺតម្លៃវាធ្លាក់ចុះតែម្ដង។

លោកបានបន្តថា តាមព័ត៌មានជារួមបណ្ដារោងម៉ាស៊ីន ដែលអ្នកនាំចេញបានប្រមូលទិញស្រូវស្តុកទុក គឺមកដល់ពេលនេះ គឺអាចមានសមត្ថភាពស្តុកប្រមាណជាកន្លះលានតោនទេ ដូច្នេះនៅពេលដែលស្រូវវាជុញ វាពេញឃ្លាំង គេលែងទិញ គឺវាធ្លាក់ចុះតែម្ដង ដូច្នេះសម្រាប់អ្នកដែលមានលទ្ធភាពគួររៀបចំកន្លែងស្តុកសម្រាប់សម្រាំងទុកពេលឡើងថ្លៃវិញ។

លោកបានបន្តថា សព្វថ្ងៃនេះ បណ្ដារោងម៉ាស៊ីន ដែលកំពុងតែសម្រួលលើការនាំចេញអង្ករ ទៅកាន់ទីផ្សារអន្តរជាតិ គឺនៅទីមួយខ្វះទុនពង្រីកកន្លែងស្តុក ទីពីរគឺទុនប្រមូលទិញស្រូវ។ តាមដឹង គឺ២០០ទៅ៣០០លានដុល្លារនៅក្នុងមួយឆ្នាំ។

ជុំវិញបញ្ហានេះលោក សុង សារ៉ន ប្រធានក្រុមហ៊ុន អេមរ៉ូយស៍ ខេមបូឌា ដែលជាក្រុមហ៊ុន នាំចេញអង្ករមួយធំនៅកម្ពុជា បានអ្នកសារព័ត៌មានថា ឃ្លាំងស្រូវក្រុមហ៊ុនលោក និងរបស់ក្រុមហ៊ុនឯកជន ទូទាំងប្រទេសពេញ ហើយទោះបីជាពេលនេះ ប្រជាកសិករកំពុងតែបន្តប្រមូលផលនៅឡើយក៏ដោយ។

លោកបានអះអាងថា ស្រូវនៅដើមដៃពិសេសគឺស្រូវក្រអូប ថ្លៃពី១.១២០ ទៅ១.១៥០រៀលក្នុងមួយគីឡូក្រាម។ រហូតមកដល់ពាក់កណ្ដាល ខែវិច្ឆិកានេះ ថ្លៃស្រូវធ្លាក់មកត្រឹម ១.០៥០ ទៅ១.០៨០ រៀលក្នុងមួយគីឡូក្រាម ហើយតម្លៃស្រូវនេះ វាអាចនឹងបន្តធ្លាក់ថ្លៃដល់ ៩៥០រៀលក្នុងមួយគីឡូក្រាម បន្តទៀត ។

លោកបានបន្តថា នៅដើមរដូវនេះក្រៅពីស្រូវក្រអូបចេញ គឺនៅមិនទាន់មានហាងឆេងទេ ដោយសារតែពេលនេះភាគច្រើនរោងម៉ាស៊ីនសម្រុក ប្រមូលទិញស្រូវក្រអូបដែលមានទីផ្សារនាំចេញសិន ។

ពាក់ព័ន្ធ នឹងបញ្ហាស្រូវអង្ករនេះដែរ សម្ដេចតេជោ ហ៊ុន សែន បានមានប្រសាសន៍នា ពិធីផ្សព្វផ្សាយគោល-នយោបាយជាតិ នៃលទ្ធផលចុងក្រោយជំរឿនកសិកម្ម នៅកម្ពុជាឆ្នាំ២០១៣ នាវិមានសន្តិភាព នៅព្រឹកថ្ងៃ ព្រហស្បត្តិ៍ ទី១០ ខែធ្នូ ថាកម្ពុជា គឺបានទទួលជោគ-ជ័យ នៅក្នុងផែនការជំរុញផលិតកម្មស្រូវ តែការនាំចេញអង្ករ គឺមិនទាន់សម្រេចគោលដៅនៅឡើយទេ។

សម្ដេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់ថា យើងបានសម្រេចជោគជ័យនៅក្នុងការជំរុញផែនការ ផលិតកម្មស្រូវដោយប្រែក្លាយ ពីប្រទេសដែលនាំចូលស្បៀង មកសល់ស្រូវប្រមាណជា ៥ លានតោននៅក្នុងមួយឆ្នាំ ឬប្រមាណ ជាអង្ករ៣លានតោន ប៉ុន្តែគោលដៅ នៃការនាំចេញអង្ករ ១លានតោននា ឆ្នាំ២០១៥ នេះគឺអាចសម្រេចបានត្រឹមតែប្រមាណជា ៥០០.០០០តោនប៉ុណ្ណោះ ពោលគឺប្រមាណជា ៥០ ភាគរយ។

សម្ដេចតេជោ បានបន្តទៀតថា មូលហេតុមិនដល់គោលដៅ គឺដោយសារតែកត្តាពីរ គឺកត្តាអត្តនោម័ត និងកត្តាសត្យានុម័ត។ ដោយកត្តាអត្តនោម័តគឺកម្ពុជាធ្លាប់ជាប្រទេសនាំចូលស្បៀងនាំឲ្យអ្នកវិនិយោគទុន មិនទាន់មើលឃើញ ហើយកម្ពុជានៅខ្វះខាតការវិនិយោគលើម៉ាស៊ីន លើថវិការ និងផលិតកម្មផ្សេងៗ រីឯកត្តាសត្យានុម័តវិញនោះ គឺដោយសារតែ អង្ករឥឡូវនេះមានការប្រកួតប្រជែងច្រើនប្រទេសផលិតស្រូវ និងអង្ករមានច្រើន ដូច្នេះហើយបានជាមានការប្រកួតប្រជែងខ្ពស់៕

មិនមែនតែតម្លៃស្រូវទេ សូម្បីតែផលិតផលកសិកម្មដទៃទៀតដូចជា កៅស៊ូ ដំឡូងមីដូងប្រេង ដែលដាំដោយកសិករ និងអ្នកវិនិយោគទុនមួយចំនួនក៏កំពុងតែប្រឈមមុន នឹងបញ្ហាត្រដាបត្រដួស ដោយសារតែការធ្លាក់ចុះនូវតម្លៃរបស់វាផងដែរ។

*ដោយអរិយបុត្រ*

# ចាស់ៗចង់ឲ្យយុវជនយកចិត្តទុកដាក់អំពីកីឡានិងការរៀនសូត្រ



*យុវជនប្រកួតកីឡានៅទីក្រុងភ្នំពេញកាលពីថ្ងៃទី០១ មករា ២០១៦។ សហការី*

ជាមួយនឹងកំណើន នៃតម្រូវការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និងសកម្មភាពអវិជ្ជមានផ្សេងៗ នៅក្នុងសង្គមចាស់ៗជំនាន់មុន ចង់ឲ្យយុវជនកម្ពុជាសម័យបច្ចុប្បន្ន យកចិត្តទុកដាក់នឹងវិស័យកីឡា និង ការរៀនសូត្រ ។

លោក ឡេង សុចិត្រា ជាប្រជាពលរដ្ឋនៅសង្កាត់ ៧ មករា ខណ្ឌ៧មករា រាជធានីភ្នំពេញ បានមានប្រសាសន៍បញ្ជាក់ថា "ទាំងខ្ញុំទាំងគេនៅក្នុងនាមជាឪពុកម្តាយមួយរូប ឃើញកូនគេលេង កីឡា និងរៀនសូត្រ គឺសប្បាយចិត្ត"។

លោកបានបន្តទៀតថា នៅក្នុងនាមជាអាណាព្យាបាល នាសម័យបច្ចុប្បន្ននេះ នរណាក៏ព្រួយបារម្ភដែរ អំពីភាពអវិជ្ជមានផ្សេងៗដែលកើតមានឡើងនៅក្នុងសង្គមកម្ពុជា ជាពិសេសគឺបញ្ហាអសកម្មដែលកំពុងតែកើតឡើង ដែលមានដូចជា គ្រឿងញៀន គ្រឿងស្រវឹង អំពើហិង្សាល្បែងស៊ីសង កន្លែងពាលា និងអាវ៉ាសែ ជាក្លិបរាត្រី ជាបា មួយចំនួន ដែលកំពុងកើតមានឡើងជាច្រើនកន្លែង។

លោកបានបញ្ជាក់ថា "សម័យនេះ គឺជាសម័យបំពុលសង្គមជាពិសេស គឺក្មេងៗជាយុវវ័យដែលខ្វីទាំងគំនិត ខ្វីទាំងការគិត និងខ្វះបទពិសោធន៍ ដូច្នេះពេលឃើញក្មេងៗ លេងកីឡា រៀនសូត្រ ខ្ញុំមានអារម្មណ៍មោទនភាពចំពោះពួកគេ"។

លោកបានបញ្ជាក់ថា "កូនខ្ញុំវានៅតិចតួចនៅឡើយទេ គឺត្រឹមតែ ៤ ទៅ១០ ឆ្នាំទេ ប៉ុន្តែ ខ្ញុំពិតជាបារម្ភ ដោយសារតែ គ្រឿងស្រវឹង គ្រឿងញៀន និង កន្លែង ពាលា អាវ៉ាសែទាំងនេះ កន្លែងណាក៏ឃើញដែរ ចេញតែពីផ្ទះមកនោះ"។

លោក ហេង ពិទូរ ជាអាណាព្យាបាលនៃយុវជនពីររូប បានឲ្យដឹងថា ឥឡូវនេះ មិនចាំបាច់ដល់ចេញពីផ្ទះនោះទេ នៅតែក្នុងផ្ទះក៏ឃើញគ្រឿងស្រវឹង និងកន្លែងអស់ទាំងនោះដែរ ។

លោកបានបន្តទៀតថា សម័យនេះទៅហើយហាមម៉េចក៏មិនបានដែរ សំខាន់គឺមានតែពន្យល់ និងលើកទឹកចិត្តហើយព្យាយាម ទាញអារម្មណ៍ពួកគេ ដោយសារតែហាមម៉េច បើបើកទូរទស្សន៍ ឃើញសុទ្ធតែ គ្រឿងស្រវឹង កម្មវិធីណាក៏ដូចជាកម្មវិធីណា សុទ្ធតែឧបត្ថម្ភដោយក្រុមហ៊ុនគ្រឿងស្រវឹង។

លោកបានបញ្ជាក់ថា "កន្លែងរៀន និងកន្លែងលេងកីឡាអី គឺកម្រឃើញព័ត៌មាន ឬផ្សាយពាណិជ្ជកម្មណាស់ តែបើក្លឹបរាត្រី ហើយរហូតដល់កន្លែងខារ៉ាអូខេ ដែលឥឡូវគេហៅថា ខេធីវី គឺឮញឹកញាប់ជាង"។

លោកបានបន្តទៀតថា ដោយសារបញ្ហាទាំងអស់នេះលោកបានអះអាងថា អាណាព្យាបាលមួយចំនួន កំពុងតែព្យា-យាមចំណាយពេល នៅជាមួយនឹងបុត្រធីតារបស់ពួកគេ ហើយព្យាយាមណែនាំគេឲ្យទៅលេងកីឡា ដូចជា ហែលទឹក កាយសម្ពន្ធផ្សេងៗ ទាត់បាល់ ... ។

តាមការអះអាងរបស់ លោក ពិទូរ លោកក៏ជាអាណាព្យាបាលម្នាក់ដែលមានបំណងចង់យកគោលគំនិតនេះដែរ ប៉ុន្តែនៅពេលនេះកូនរបស់លោកវាធំៗអស់ហើយ។

លោកបានបញ្ជាក់ថា វាអាចជាការប្រសើរប្រសិនបើយើងអាចចំណាយពេលយកចិត្តទុកដាក់នឹងបញ្ហានេះដែរដោយសារតែ ភាពជិតស្និទ្ធ ភាពកក់ក្តៅ តាមរយៈសកម្មភាពទាំងនេះ វាគឺជាបច្ច័យមួយដែលអាចឲ្យក្មេងៗមានអារម្មណ៍ថាមានគ្រួសារសំខាន់ ប៉ុន្តែប្រសិនបើ គ្រួសារខ្វះសកម្មភាពពួកគេអាច នឹងងាយធ្លាក់នៅក្នុងអំពើ និងការអូសទាញពីសង្គម។

លោកពិទូរ បានបញ្ជាក់ថា "ខ្ញុំវាហួសពេលហើយ កូនគេមានវ័យតូចបំផុត ក៏ ១៧ឆ្នាំដែរ ប៉ុន្តែ ខ្ញុំនៅតែតាមឃ្លាំមើលពួកគេជានិច្ច"។

លោកបានបញ្ជាក់អំពីអារម្មណ៍របស់លោកផ្ទាល់ថា "នៅថ្ងៃចុងសប្តាហ៍ បើឃើញកូនស្លៀកសម្លៀកបំពាក់កីឡា ហើយប្រាប់ថាទៅទាត់បាល់ ទៅលេងសីហើយមកវិញ ឃើញកូនៗអង្គុយមើលសៀវ ភៅ គឺសប្បាយចិត្ត ប៉ុន្តែបើថ្ងៃណាឃើញគេស្លៀកពាក់ស្អាត ហើយសុំលុយថា ទៅជប់លៀង គឺពិបាកចិត្តតែម្តង "។

លោកបានបន្តថា ពេលកូនសុំម្តងម្តាលមិនអាចបដិសេធបានទេ ពីព្រោះនេះ គឺជាទំនាក់ទំនងសង្គម ប៉ុន្តែទឹកចិត្តអាណាព្យាបាល គឺអនុញ្ញាតទាំងបារម្ភ ពីព្រោះកន្លែងពាលានិងទិដ្ឋភាពអវិជ្ជមាននោះវាច្រើនហួស ។

លោក សុចិត្រា បានបន្តថា ឥឡូវនេះក្រៅពីកន្លែងពាលា កន្លែងកីឡាកន្លែងមានប្រយោជន៍ សម្រាប់កុមារ និងក្មេងៗ ក៏មានដែរ ទោះបីជាមិនអាចប្រៀបធៀបនឹងចំនួនកន្លែងពាលា ទាំងនោះមែន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយតម្លៃនៃកន្លែងទាំងនោះគឺវាថ្លៃ ។

លោកបានបញ្ជាក់ថា "កន្លែងទាំងនោះ អ្នកធម្មតាដូចខ្ញុំអាចទៅបាន ប៉ុន្តែមិនអាចញឹកញាប់បានទេ ពីព្រោះវាថ្លៃ ។ កន្លែងខ្លះ គ្រាន់តែម្នាក់យក ថ្លៃសំបុត្រចូល៥ ដុល្លារ អីហើយ នៅក្នុងម្នាក់ "។

លោកបានបន្តថា ដើម្បីសម្រួលដល់ប្រជាពលរដ្ឋ ក្រសួងអប់រំយុវជន និងកីឡា អាជ្ញាធរដែនដី បើសិនជាយកចិត្តទុកដាក់បង្កើតកន្លែងសង្គមដូច្នេះឲ្យបានច្រើនកន្លែង ប្រហែលជាប្រសើរ ។

លោកបានបន្តទៀតថា កន្លែងដែលមានប្រយោជន៍សម្រាប់កុមារ មានច្រើនដែរ ដូចជាកន្លែងរៀន គូរគំនូរ កន្លែងរៀនតន្ត្រី កន្លែងហាត់ប្រាណ ផ្សេងៗ ប៉ុន្តែ តម្លៃឈ្នួលនោះ គឺវាថ្លៃ។

*អរិយបុត្រ*

# ក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា ចុះសួរសុខទុក្ខទណ្ឌិតនៅកំពត



*លោកអភិបាល អូលីវីយេ និងតំណាងសាសនានានាចែកអំណោយដល់ទណ្ឌិតនៅខេត្តកំពត។ រូបថតដោយ៖ សម្ផស្ស*

ព្រះសហគមន៍កាតូលិក បានដឹកនាំគណៈប្រតិភូអន្តរសាសនាកម្ពុជា មានពុទ្ធសាសនា ឥស្លាម និងគ្រីស្តសាសនា ចូលសួរសុខទុក្ខ និងចែកអំណោយដល់ទណ្ឌិតក្នុងពន្ធនាគារខេត្តកំពត កាលពីព្រឹកថ្ងៃទី០៤ មករា ២០១៦នេះ ។

ក្នុងពិធីនោះដែរ មានការអញ្ជើញចូលរួមជាអធិបតីពីសំណាក់លោកអូលីវីយេ ផ្មីតអីវស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ លោកនាក់ យិតថូ ប្រធានមន្ទីរធម្មការនិងសាសនាខេត្តកំពត ព្រះតេជគុណចាន់ សុវណ្ណ ព្រះមេគុណគណៈធម្មយុត្តិកនិកាយខេត្តកំពត ឯកឧត្តមលី សារី ប្រធានអ៊ីមាំនៃគណៈឥស្លាមក្នុងខេត្ត រួមទាំងព្រះសង្ឃ អស់លោកបូជាចារ្យ លោក លោកស្រី ជាតំណាងគ្រូគង្វាល រួមនិងបងប្អូនជាគ្រីស្តបរិស័ទជាច្រើនរូបទៀត។

លោកអភិបាលអូលីវីយេ ផ្មីតអីស្លែរ មានប្រសាសន៍ថា នៅថ្ងៃនេះជាឱកាសមួយ យើងរួមគ្នាមកពីគ្រប់សាសនាទាំងអស់ ដែលមានតំណាងមកពីខាងព្រះពុទ្ធសាសនា ឥស្លាមសាសនា ប្រូតស្តេង់ និងកាតូលិក ដែលបានចូលរួមនៅថ្ងៃនេះ។ ថ្ងៃនេះជាថ្ងៃពិសេស ដែលយើងធ្វើដំណើររួមជាមួយគ្នា ដើម្បីបង្ហាញសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដល់បងប្អូនទាំងអស់ ។

លោកអភិបាលបានបន្តថា "គ្រប់សាសនានីមួយៗ បានខិតខំបង្ហាញធម៌មេត្តាករុណា តាមជំនឿសាសនារបស់ខ្លួន ដោយសេចក្តីស្រឡាញ់។ សូមឲ្យបងប្អូន ដែលរស់នៅទីនេះ ចូរចេះរួបរួមសាមគ្គីគ្នាមានចិត្តមេត្តាករុណាប្រណីសន្តោស ស្រឡាញ់រវាងគ្នានឹងគ្នាដើម្បីភាពសុខសាន្តជាមួយគ្នា។ បងប្អូនដែលនៅទីនេះ ចូរខិតខំកែប្រែខ្លួនឲ្យបានល្អ ដើម្បីក្លាយជាពលរដ្ឋល្អនៅពេលចាកចេញពីទីនេះ ត្រឡប់ទៅជួបជុំគ្រួសារ និងសង្គមជាតិវិញ"។

លោកអ៊ែម បូរ ប្រធានពន្ធនាគារខេត្តកំពត បានលើកឡើងថា សម្រាប់ពន្ធនាគារខេត្តកំពតសព្វថ្ងៃនេះមានអ្នកជាប់ឃុំឃាំងចំនួនជាង៤០០នាក់ ។ ក្នុងនាមថ្នាក់ដឹកនាំនិងមន្ត្រីពន្ធនាគារខេត្តកំពត លោកសូមថ្លែងអំណរគុណចំពោះសមាជិកក្រុមប្រឹក្សាអន្តរសាសនាកម្ពុជា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមសាកសួរសុខទុក្ខដល់ជនជាប់ក្នុងមន្ទីរឃុំឃាំងនាឱកាសនេះ។ ពិធីនេះ គឺជាការលើកទឹកចិត្តមួយ ដល់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីអនុរក្សពន្ធនាគារ ក្នុងការចូលរួមជួយដល់ជនដែលបានជាប់ឃុំឃាំងទាំងអស់ធ្វើការកែប្រែខ្លួនទៅជាមនុស្សល្អវិញ ។

ព្រះតេជគុណចាន់ សុវណ្ណ ព្រះមេគុណគណធម្មយុត្តិកនិកាយខេត្តកំពត បានមានសង្ឃដីកាថា ចាប់ពីពេលនេះតទៅ សូមបងប្អូនខិតខំកែប្រែខ្លួនដោយលះបង់នូវចិត្តលោភៈ ទោសៈ មោហៈ ដើម្បីក្លាយជាមនុស្សល្អវិញ។ ក្រោយពេលបងប្អូនចាកចេញពីទីនេះ បងប្អូនចូលរួមជួយកសាងសង្គមគ្រួសារខ្លួន និង ជួយកសាងប្រទេសជាតិនៅថ្ងៃអនាគត។

ជាមួយគ្នានេះលោកលី សារី ជាអ៊ីមាំ និង ជាប្រធានគណឥស្លាមប្រចាំខេត្តកំពត បានមានប្រសាសន៍ថា មនុស្សយើងម្នាក់ៗនរណា ក៏ធ្លាប់បានប្រព្រឹត្តកំហុសនោះដែរ ប៉ុន្តែការកែប្រែខ្លួនគឺជារឿងដែលសំខាន់។ បងប្អូនបានមកនៅទីនេះមួយរយៈ ជាឱកាសមួយសម្រាប់បងប្អូនរិះគិតឡើងវិញ នូវទោសកំហុសរបស់ខ្លួន ហើយនិងធ្វើការផ្លាស់ប្តូរ ទាំងចិត្តគំនិត និងអត្តចរិត ក្លាយជាមនុស្សល្អឡើងវិញនៅពេលក្រោយ ។

នៅក្នុងឱកាសនោះដែរ សាសនានីមួយៗបានអធិដ្ឋាន និងប្រោះទឹកព្រះពរជូនអ្នកជាប់ឃុំផងដែរ។

អំណោយដែលបានចែកជូនបងប្អូននោះរួមមាន អាហារ និងកញ្ចប់សម្ភារប្រើប្រាស់មួយចំនួន សម្រាប់បងប្អូនដែលជាប់ឃុំមានចំនួនជាង ៤០០នាក់ ព្រមទាំង មន្ត្រីអនុរក្សពន្ធនាគារផងដែរ។ ពន្ធនាគារខេត្តកំពតបានផ្លាស់ទៅកាន់ទីតាំងថ្មីកាលពីចុងឆ្នាំ២០១៥កន្លងទៅ ស្ថិតនៅឃុំកោះតូច ចម្ងាយជាង១០គីឡូម៉ែត្រពីទីក្រុងកំពត។

ដោយ ឡុង សម្ផស្ស

## ច្បាប់ចរាចរណ៍ ផ្លូវគោកថ្មី

មាត្រា២៨៖

ការប្រើប្រាស់សូរសព្ទ យានជំនិះត្រូវអនុវត្តដូចខាងក្រោម៖

" ការប្រើប្រាស់សញ្ញាសូរសព្ទ "ស៊ីផ្លេ" ត្រូវអនុញ្ញាតឲ្យប្រើប្រាស់តែនៅពេលថ្ងៃ ដើម្បីឲ្យដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀត ជៀសវាងនូវគ្រោះថ្នាក់ ដែលអាចកើតមានដោយយថាហេតុ និងដើម្បីសុំផ្លូវនៅក្រៅទីប្រជុំជន។"

នៅពេលយប់សញ្ញាសូរសព្ទ "ស៊ីផ្លេ" ត្រូវជំនួសដោយសញ្ញាភ្លើងហ្វាកូតឆ្លាស់គ្នា សម្រាប់ឲ្យដំណឹងដល់អ្នកប្រើប្រាស់ផ្លូវដទៃទៀត ដើម្បីជៀសវាងនូវគ្រោះថ្នាក់ និងសុំផ្លូវ។

" សញ្ញាសូរសព្ទ ពិសេសអាចប្រើបានគ្រប់ពេលវេលា ក្នុងពេលកំពុងបំពេញភារកិច្ច ចំពោះយានពន្លត់អគ្គិភ័យ យានសង្គ្រោះរបស់មន្ទីរពេទ្យ យាននគរបាលយោធា កងរាជអាវុធហត្ថ ក្បួនគណៈប្រតិភូ ក្បួនថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក្បួនយានដែលមាន នគរបាលចរាចរណ៍ផ្លូវគោកនាំមុខ។

" សញ្ញាសូសព្ទ ត្រូវប្រើក្នុងរយៈពេលខ្លី គឺមិនយូរជាងការចាំបាច់ឡើយ លើកលែងតែមានការប្រកាសអាសន្ន។

" សញ្ញាសូរសព្ទ ស៊ីផ្លេខ្យល់ត្រូវហាមប្រើនៅក្នុងទីក្រុង ទីប្រជុំជន ឬនៅជិតមន្ទីរពេទ្យ។

# ព្រះសហាគមន៍កាតូលិក កំពុងរស់រវើក ប៉ុន្តែត្រូវការបន្ថែមជីវិតខាងផ្លូវវិញ្ញាណ



*លោកបូជាចារ្យសួន ហង្សលី ចែកអំណោយជូនអ្នកក្រីក្រនៅមណ្ឌលសកម្មភាពភ្នំពេញថ្មី។ រូបថតដោយ៖ សុវណ្ណា*

លោកបូជាចារ្យសួន ហង្សលី ជាបូជាចារ្យខ្មែរដែលបានទៅសិក្សានៅប្រទេសបារាំងអំពីទេវវិទ្យាខាងផ្លូវវិញ្ញាណបានត្រឡប់មកកម្ពុជាវិញ ពីដើមខែតុលា ២០១៥នេះ។ សព្វថ្ងៃលោកមានតួនាទីជាបូជាចារ្យទទួលខុសត្រូវ មណ្ឌលសកម្មភាពភ្នំពេញថ្មី និងជាគណៈកម្មការអប់រំជំនឿសម្រាប់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ អ្នកនាំសារ បានជួបសម្ភាសជាមួយលោកអំពីការសិក្សា និងគោលដៅសម្រាប់ការអភិវឌ្ឍន៍ផ្លូវវិញ្ញាណរបស់គ្រីស្តបរិស័ទកម្ពុជា។

អ្នកនាំសារ៖ តើការសិក្សានៅប្រទេសបារាំង លោករើសផ្នែកអ្វីដែរ?

សួន ហង្សលី៖ មុនទៅបារាំងដើម្បីរៀន ខ្ញុំគិតថា នឹងជ្រើសរើសយកផ្នែកអប់រំជំនឿ។ ប៉ុន្តែពេលទៅដល់ ខ្ញុំបានពិភាក្សាជាមួយនឹង លោកបូជាចារ្យខ្មែរ គឺលោកឪពុកប៉ូល គាត់មានយោបល់ប្រាប់ខ្ញុំថា យើងជាបូជាចារ្យខ្មែរ៤នាក់គួរឲ្យរៀនមុខវិជ្ជាខុសគ្នាដើម្បីជួយកសាងព្រះសហគមន៍នៅស្រុកខ្មែរ។ ដូច្នេះ ខ្ញុំក៏សម្រេចរៀនមុខវិជ្ជាខាងផ្លូវវិញ្ញាណ។

អ្នកនាំសារ៖ ហេតុអ្វីមុខវិជ្ជានេះត្រូវចំណាយពេលរហូតដល់ទៅ៨ឆ្នាំ?

សួន ហង្សលី៖ មុនដំបូងគេតម្រូវឲ្យយើងរៀនអំពីទេវវិទ្យា តែគេត្រូវការសញ្ញាបត្របញ្ជាក់អំពី បាក់កូឡូរ៉េអា ខាណូនីក ( Bacoloréa Canoneque ) ជាសញ្ញាបត្រ ពីទេវវិទ្យាល័យស្រុកខ្មែរតែនៅពេលនោះ ខ្ញុំអត់មានទេ។ ដូច្នេះហើយ ខ្ញុំត្រូវការរយៈពេល៨ឆ្នាំ ដោយក្នុងនោះ១ឆ្នាំកន្លះដំបូង ខ្ញុំត្រូវរៀនភាសាបារាំង ហើយបីឆ្នាំទៀត ខ្ញុំត្រូវរៀនដើម្បីប្រលងយក បាក់កូឡូរ៉េអា ខាណូនីក បន្ទាប់មកទៀតខ្ញុំក៏បន្តយកអនុបណ្ឌិតទេវវិទ្យានៃជីវិតខាងផ្លូវវិញ្ញាណរយៈពេល ៤ឆ្នាំទៀត។

អ្នកនាំសារ៖ តើមុខវិជ្ជានេះមានប្រយោជន៍អ្វីខ្លះដល់លោកផ្ទាល់ និងគ្រីស្តបរិស័ទនៅកម្ពុជា?

សួន ហង្សលី៖ ការសិក្សានៅទីនោះគឺបានជួយដល់គំនិតរបស់ខ្ញុំ។ យើងអាចយកគំនិតខ្លះពីគេដើម្បីកែច្នៃ ធ្វើយ៉ាងម៉េចពន្យល់ដល់អស់អ្នកដែលត្រូវការនៅស្រុកខ្មែរ។ ឧទាហរណ៍ ឃ្លាខ្លះនៅក្នុងភាសាខ្មែរ យើងស្តាប់មិនសូវយល់ទេ តែខ្ញុំអាចផ្ទៀងផ្ទាត់ពីភាសាបារាំងមកវិញដើម្បីស្វែងរកអត្ថន័យពិតប្រាកដ។ ម្យ៉ាងទៀត អំពីមុខវិជ្ជាខាងផ្លូវវិញ្ញាណ គឺជួយដល់ខ្ញុំស្គាល់អំពីរបៀបរស់នៅខាងផ្លូវវិញ្ញាណខ្លះៗ ហើយខ្ញុំសង្ឃឹមថា ពេលក្រោយខ្ញុំអាចជួយណែនាំគេបន្តិចៗ ប្រហែលជាមានប្រយោជន៍សម្រាប់គេ។

អ្នកនាំសារ៖ តើលោកបូជាចារ្យ យល់ឃើញយ៉ាងដែរ ចំពោះជីវិតផ្លូវវិញ្ញាណរបស់គ្រីស្តបរិស័ទនៅកម្ពុជា?

សួន ហង្សលី៖ ពេលខ្ញុំត្រឡប់មកវិញ ខ្ញុំឃើញថាស្រុកខ្មែរប្លែក និងមានការអភិវឌ្ឍន៍ច្រើន។ នៅភ្នំពេញមានអាគារ និងមនុស្សច្រើនជាងមុន ហើយម្យ៉ាងទៀត ការងារក៏មានច្រើនជាងមុន នាំឲ្យមនុស្សរវល់អំពីការងារ ដើម្បីចិញ្ចឹមជីវិត រវល់នឹងឧបករណ៍ទំនើបៗ ឬក៏សម្ភារផ្សេងៗដូចជាឡាន ទូរស័ព្ទដៃជាដើម។ ហើយខ្ញុំឃើញព្រះសហគមន៍ក៏មានការងារច្រើនខាងសង្គម ជួយដល់អ្នកក្រីក្រ និស្សិត ក្មេងៗឲ្យទទួលការអប់រំ ជាពិសេសអ្នកជំងឺ និងការអភិវឌ្ឍន៍តាមភូមិ។ ក៏ប៉ុន្តែខ្ញុំពិនិត្យមើលនៅក្នុងព្រះសហគមន៍ សកម្មភាពផ្លូវវិញ្ញាណមានខ្លះៗដែរ គឺមានការអធិដ្ឋានរាល់ខែសម្រាប់អ្នកស្តាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ជាបព្វជិត-ជិតា។ ហើយមួយទៀតដែរ ខ្ញុំឃើញថាតាមព្រះសហមន៍មានអធិដ្ឋានតេហ្សេ និងអធិដ្ឋានផ្តាំ នេះក៏ជួយដែរ តែតាមផ្លូវវិញ្ញាណវាហាក់ដូចជាខ្វះអ្វីម្យ៉ាងជួយឲ្យគ្រីស្តបរិស័ទស៊ីជម្រៅអំពីជំនឿដែលគេបានទទួលពីព្រះសហគមន៍។

អ្នកនាំសារ៖ ចំណុចនេះ តើលោកគួរជួយព្រះសហគមន៍យ៉ាងណា?

សួន ហង្សលី៖ តាមពិតគ្រីស្តបរិស័ទគេមិនត្រឹមតែមក ចូលរួមអធិដ្ឋានមួយពេលៗ ប៉ុន្តែគេត្រូវការពេលវេលាខ្លះ ឧទាហរណ៍៣ថ្ងៃឬមួយអាទិត្យ ដើម្បីសំណាក់ធម៌សញ្ជឹងគិតអំពីព្រះជាម្ចាស់ សេចក្តីស្រឡាញ់របស់ព្រះអង្គ ដើម្បីឲ្យជំនឿចាក់ឫស ក្នុងដួងចិត្តរបស់គេ។ នៅក្នុងស្រុកខ្មែរខ្ញុំគិតថាអត់សូវមានទេ គឺមានតែសម្រាប់បូជាចារ្យ។ អ្វីដែលខ្ញុំចាប់អារម្មណ៍គឺឃើញមានគ្រីស្តបរស័ទជាច្រើននាក់ នៅក្នុងប្រទេសខ្មែរដែលជ្រមុជទឹកថ្មី ហើយក្រោយមក១ឆ្នាំ ឬ ២ឆ្នាំ គេអត់សូវមកព្រះវិហារ មានខ្លះទៀតត្រឡប់ទៅវត្តវិញក៏មានដែរ។ ខ្ញុំចាប់អារម្មណ៍ ចំពោះចំណុចនេះឯងព្រោះវាជាមុខងារមួយពិសេស សម្រាប់កម្មវិធីអប់រំជំនឿគឺធ្វើយ៉ាងណាដើម្បីឲ្យគ្រីស្តបរិស័ទ យល់ច្បាស់អំពីជំនឿដើម្បីជួយគេឲ្យទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ហើយនឹងរីករាយចែករំលែកដល់អ្នកដទៃ រីករាយក្នុងការអធិដ្ឋាននិងការចូលរួមថ្វាយអភិបូជាដែរ។

អ្នកនាំសារ៖ លោកបូជាចារ្យនឹងមានគម្រោងរៀបចំផែនការអ្វីខ្លះ ដើម្បីជួយដល់ផ្លូវវិញ្ញាណនេះ?

សួន ហង្សលី៖ ខ្ញុំមិនទាន់មានគម្រោងធ្វើអ្វីទេ គ្រាន់តែឆ្នាំនេះខ្ញុំចាប់ផ្តើមធ្វើការនៅក្នុងព្រះសហគមន៍ភ្នំពេញថ្មី និងទទួលខុសត្រូវលើកម្មវិធីអប់រំជំនឿរបស់គ្រីស្តបរិស័ទ ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។ គម្រោងរបស់ខ្ញុំទី១គឺ ខ្ញុំត្រូវការស្គាល់អំពីព្រះសហគមន៍នីមួយៗ។ ចំណុចទី២គឺ ខ្ញុំគិតថា ប្រសិនបើអាចធ្វើបានលោកបូជាចារ្យម្នាក់ៗតាមតំបន់គួរតែរៀបចំកម្មវិធីណែនាំគ្រីស្តបរិស័ទឲ្យយកចិត្តទុកដាក់អំពីសំណាក់ធម៌។ វាជាការលំបាកណាស់ ដោយសារមនុស្សទាំងអស់រវល់ តែបើអាចធ្វើទៅបាន វាជួយឲ្យគ្រីស្តបរិស័ទយល់ច្រើន។ ក្រៅពីនេះខ្ញុំត្រូវស្រាវជ្រាវអំពីអគ្គសញ្ញាលើកលែងទោសតាមសំណើរលោកអភិបាល។

អ្នកនាំសារ៖ តើមួយឆ្នាំនឹងអាចមានប៉ុន្មានដងដែរសម្រាប់គ្រីស្តបរិស័ទ?

សួន ហង្សលី៖ ខ្ញុំគិតថា បើអាចធ្វើបានគួរតែធ្វើ១ឆ្នាំ២ដងសម្រាប់ព្រះសហគមន៍នីមួយៗ តែវាអាស្រ័យលើបូជាចារ្យទទួលខុសត្រូវ ហើយមើលសភាពការណ៍នៅក្នុងរបស់លោក ប៉ុន្តែបើអាចធ្វើឲ្យបានច្រើនជាងកាន់តែប្រសើរ។

*ដោយកញ្ញា*

# គ្រីស្តបរិស័ទក៏ជាកោសិកាសង្គមមួយដ៏រស់រវើកនៅកម្ពុជា



*យុវជនកាតូលិកចុះសួរសុខទុក្ខនិងជូនម្ហូបចាស់ជរាតាមផ្ទះ ។ រូបថតដោយ៖ សហការី*

នៅកម្ពុជាត្រូវបានគេដឹងថា មានប្រជាពលរដ្ឋប្រមាណជា ៩៥ភាគរយ គឺមានជំនឿលើព្រះពុទ្ធសាសនា ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏កម្ពុជានៅមានប្រជាពលរដ្ឋ ដែលមានជំនឿលើសាសនាផ្សេងៗទៀត ហើយនៅក្នុងនោះមានគ្រីស្តសាសនាជាពិសេសគឺកាតូលិក ដែលកំពុង តែចូលរួមយ៉ាងសកម្មក្នុងដំណើរការសង្គមនៅកម្ពុជាផងដែរ។

លោក មិន ឃិន រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនាមានប្រសាសន៍នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយ "ការបញ្ជ្រាបទស្សនាទានសីលធម៌ សាសនា ដើម្បីសុខដុមនីយកម្មនៅកម្ពុជា ដែលរៀបចំនៅមជ្ឈមណ្ឌលពិព័ណ៌កោះពេជ្រ កាលពីថ្ងៃទី១៤ ធ្នូ ២០១៥ កន្លងទៅថ្មីៗនេះថា សាសនាទាំងអស់នៅលើពិភពលោកមានកំណើត និងប្រភពខុសៗគ្នា ប៉ុន្តែដោយឡែកនៅកម្ពុជា គឺសាសនាមានកំណើតឡើងវិញតំណាលគ្នា គឺថ្ងៃទី ០៧ មករា ១៩៧៩ ។

លោកបានបន្តទៀតថា មកដល់ពេលបច្ចុប្បន្ននេះ សាសនាទាំងអស់រីកចម្រើនគួរជាទីមោទនៈ មានសណ្តានចិត្តចេះយោគយល់គ្នា អធ្យាស្រ័យគ្នា និងគោរពគ្នាទៅវិញទៅមកដែលទាំងនេះ គឺជាមូលដ្ឋានគ្រឹះនៃសន្តិភាព។

លោក រដ្ឋមន្ត្រី ក៏បានមានប្រសាសន៍ឲ្យដឹងថា នៅកម្ពុជានៅពេលសព្វថ្ងៃនេះ មានអ្នកដែលមាន ជំនឿលើព្រះពុទ្ធសាសនាទាំងពីរនិកាយគឺ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយ ដែលមានព្រះសង្ឃចំនួនជិត៦០.០០០ អង្គ និងវត្តអារាមចំនួន ប្រមាណជាជិត ៥.០០០ វត្ត ជាពិសេសគឺ ពុទ្ធបរិស័ទនោះចំនួនប្រមាណជា ៩៥ ភាគរយ។ លោកបានបន្តទៀតថា ឥស្លាម មានពីរនិកាយ នឹងមានវិហារប្រមាណជាជាង ៤០០ ស្នាក់ការថ្វាយបង្គំជាង ៨០០ កន្លែង និងបរិស័ទមានចំនួនប្រមាណជាជាង ៣០០.០០០ នាក់ បន្ទាប់មក គឺគ្រីស្តសាសនា ដែលមានពីរនិកាយដែរ គឺព្រះសហគមន៍កាតូលិក និងប្រូតេស្តង់ ដែលបែកជានិកាយតូចៗជាច្រើនទៀត ដែលមានបរិស័ទ សរុបប្រមាណជា០.២៥ ភាគរយ នៃប្រជាពលរដ្ឋសរុប។

លោកបានបញ្ជាក់ថា "ថ្វីបើកម្ពុជាមានសាសនាច្រើន ប៉ុន្តែ ជាទូទៅពលរដ្ឋទាំងអស់ គឺមានសណ្តានចិត្តចេះយោគយល់អធ្យាស្រ័យគ្នា និងគោរពគ្នាទៅវិញទៅមក ដែលជាមូលដ្ឋានគ្រឹះនៃវប្បធម៌សន្តិភាព "។

រហូតមកដល់ពេលនេះកម្ពុជាត្រូវបានគេដឹងថា គឺជាកោះសន្តិភាពសាសនាមួយ ពោលគឺគេអាចនិយាយបានថា ជាដែនដីនៃសុខដុមនីយកម្មមួយ។

ជុំវិញបញ្ហានេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាថ្លែងថា ទោះបីជាកម្ពុជា ជាដែនដីនៃសុខដុមនីយកម្មលើសាសនានេះរួចហើយក៏ដោយក៏កម្ពុជាចាំបាច់ត្រូវតែយកចិត្តទុកដាក់ជំរុញ កិច្ចការនេះឲ្យមាននិរន្តភាព ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងបញ្ជាក់ថា "យើងចាំបាច់ត្រូវបន្តពង្រឹងសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនា ដោយប្រឆាំងការរើសអើង និងការបែងចែកក្នុងចំណោមប្រជាជនដែលបណ្តាលមកពីភាពខុសគ្នាខាងសាសនា សំដៅប្រែក្លាយ សក្តានុពលរបស់ សាសនាទាំងអស់ឱ្យទៅជាកម្លាំងជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ចពង្រឹងសន្តិភាពសាមគ្គីភាព ការថែរក្សាប្រពៃណីជាតិ និងលើកកម្ពស់តម្លៃសីលធម៌ ខណៈដែលកម្ពុជាកំពុងតែអបអរសាទរនូវលទ្ធផលនៃសុខដុមនីយកម្មក្នុងវិស័យសាសនា ដោយកម្ពុជាបញ្ចៀសនូវ អំពើហិង្សាសាសនាដែលជាឧត្តមប្រយោជន៍ និងកាលានុវត្តភាពធំធេងរបស់កម្ពុជា"។

សម្តេចតេជោនាយករដ្ឋមន្ត្រីថ្លែងបន្តថា ដោយឈរលើជំហរនយោបាយស្មើភាព ស្មើសិទ្ធិ និងការអនុវត្តកាតព្វកិច្ចដូចៗគ្នា ដែលកម្ពុជាត្រូវបានប្រកាន់យកតាំងពីដើមរហូតមកនេះ បានធ្វើឱ្យសង្គមកម្ពុជា យើងស្ថិតក្នុងស្ថានភាពមួយងាយស្រួលចុះសម្រុង ទោះបីមាន ជនជាតិដទៃច្រើន និងសាសនាច្រើនក៏ដោយ។

សម្តេចតេជោ ហ៊ុន សែន បានបន្តលើកឡើងថា ចំណុចនេះមិនត្រឹមតែមានមោទនភាពសម្រាប់កម្ពុជាប៉ុណ្ណោះទេក៏ប៉ុន្តែក៏ជាមោទនភាពសម្រាប់ប្រទេសក្នុងតំបន់និងពិភពលោក ចំពោះភាពជោគជ័យ នៃសុខដុមនីយកម្ម សាសនានេះ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងបន្តទៀតថា ទោះជាយ៉ាងនេះក្តី ការពង្រឹងសុខដុមនីយកម្មសាសនា គឺជាកិច្ចការចាំបាច់ ចំពោះមុខមួយដែលរាជរដ្ឋាភិបាល ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងព្យាយាមអនុវត្តគ្រប់កាលៈទេសៈ មិនអាចមើលរំលងបានឡើយ ក្នុងនោះត្រូវធ្វើឱ្យគ្រប់ជនជាតិ និងសាសនិកទាំងអស់ នៅកម្ពុជាអនុវត្តកាតព្វកិច្ចជាតិដូចៗគ្នា គឺរួបរួមសាមគ្គីគ្នា ស្នេហាជាតិ និងគោរពរដ្ឋធម្មនុញ្ញតែមួយ ព្រះមហាក្សត្រតែមួយ

ស្របតាមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ។

ជាការពិតផ្អែកតាមចំនួនស្ថិតិ ដែលលោករដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនាបានលើកឡើងខាងលើ គ្រីស្តបរិស័ទ ដែលគោរពទៅតាមជំនឿ តាមគោលការណ៍ព្រះសហគមន៍កាតូលិកនៅកម្ពុជា គឺមានចំនួនតិចធៀបនឹងក្រុមនៃសាសនាផ្សេងៗ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏គ្រីស្តបរិស័ទជាកាតូលិកបានចូលរួមចំណែកយ៉ាងសកម្ម នៅក្នុងការអភិវឌ្ឍន៍ សង្គមជាតិកម្ពុជាទាំងមូល។

គ្រីស្តបរិស័ទ ដែលគោរពទៅតាមគោលការណ៍អប់រំជំនឿតាមព្រះសហគមន៍កាតូលិក គឺកំពុងតែចូលរួមបំពេញភារកិច្ចយ៉ាងសកម្ម នៅលើផ្នែកជាច្រើននៅក្នុងសង្គមកម្ពុជា បន្ទាប់ពីទទួលការអប់រំជំនឿយ៉ាងយកចិត្តទុកដាក់ និងការសម្រេចចិត្តដ៏មោះមុតរបស់ពួកគេ។

លោកបណ្ឌិត សំ ៉ានី បច្ចុប្បន្ននេះគឺជានាយកវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យបាត់ដំបង បានមានប្រសាសន៍ថា "ខ្ញុំគឺជាគ្រីស្តបរិស័ទមួយរូប ខ្ញុំធ្លាប់ទទួលការអប់រំជំនឿពីព្រះសហគមន៍កាតូលិក ប៉ុន្តែខ្ញុំនៅតែជាពលរដ្ឋខ្មែរដែលមានតួនាទី និងភារកិច្ចជាតិបំរើជាតិ និងប្រជាពលរដ្ឋកម្ពុជាបានទាំងអស់ដូចគ្នា"។

លោកបណ្ឌិតបន្តថា រហូតមកដល់ពេលនេះ ទោះបីរូបលោកជាគ្រីស្តបរិស័ទ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏លោក និងគ្រីស្តបរិស័ទទាំងអស់នៅតែអាចធ្វើការជាមួយនឹងបងប្អូនពុទ្ធបរិស័ទ ដើម្បីសង្គមជាតិកម្ពុជាទាំងមូលបានដូចគ្នា។

លោកបណ្ឌិតបានបញ្ជាក់ថា "នៅសង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ សាសនាណាក៏ដូចសាសនាណាដែរ គឺអាចធ្វើការបម្រើជាតិបានដូចគ្នា គ្រាន់តែការអប់រំជំនឿខុសគ្នា ប៉ុន្តែបង្រៀនមនុស្សទៅគោលដៅតែមួយ គឺអប់រំមនុស្សឲ្យធ្វើអំពើល្អដូចគ"។

លោកបានបន្តថា តាមប្រវត្តិការងារកន្លងមក នៅពេលដែលយើងបង្ហាញអត្តសញ្ញាណពិតប្រាកដ នៅក្នុងសង្គមការងារសង្គមទូទៅ គឺហាក់ដូចជាមានភាពភ្ញាក់ផ្អើលបន្តិច ប៉ុន្តែក្រោយមក គឺយើងអាចធ្វើការជាមួយគ្នាបានជាធម្មតា។

លោក បណ្ឌិត បន្តរៀបរាប់ថា លោកបានចាប់ផ្តើម ទទួលយកការអប់រំជំនឿតាមគោលលទ្ធិរបស់ព្រះសហគមន៍កាតូលិក កាលនៅពេលដែលលោកនៅជាយុវជន ដែលស្នាក់នៅមណ្ឌល និស្សិត។

លោកបានបញ្ជាក់ថា "នៅពេលនោះ ប្រសិនបើខ្ញុំមិនចាប់អារម្មណ៍ នឹងជីវិតជាគ្រីស្តបរិស័ទក៏មិន ជាបញ្ហាអ្វីដែរប៉ុន្តខ្ញុំកោតសរសើរ ចំពោះការលះបង់ផលប្រយោជន៍គ្រួសារ និងកសាងជីវិតតាមព្រះគ្រីស្តរបស់លោកបូជាចារ្យ ក៏ចាប់អារម្មណ៍ទទួលយកការអប់រំជំនឿ ហើយក៏បានទទួល អគ្គសញ្ញា ជាគ្រីស្តបរិស័ទមកជារៀងរហូតមក"។

ក្រៅពីលោកបណ្ឌិត សំ ៉ានី បច្ចុប្បន្ននេះ គ្រីស្តបរិស័ទដែលទទួលការអប់រំជំនឿតាមគោលលទ្ធិនៃព្រះសហគមន៍កាតូលិក ហើយកំពុងតែចូលរួមជាសិការនៃការអភិវឌ្ឍន៍ នៅក្នុងសង្គមកម្ពុជា គឺមានជាច្រើន។ គ្រីស្តបរិស័ទទាំងនេះ គឺបានកំពុងតែបំពេញការងារ នៅក្នុងសង្គមនៅក្នុងនាមជាមន្ត្រីរាជការ ជាសាស្ត្រាចារ្យជាវេជ្ជបណ្ឌិត ជាសិស្ស ជានិស្សិតជាដើម ដែលកំពុងតែបំពេញមុខងារ និងភារកិច្ច តាមការទទួលខុស ត្រូវរៀងៗខ្លួន។

លោក សុខ ពង្សាមេត្រី ជាប្រធានគម្រោងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យាមួយរូបបានឲ្យដឹងថា ការអប់រំចិត្តគំនិត និងរបៀបរបបនៃការទទួលខុសត្រូវ ចេះប្រាស្រ័យទាក់ទង យោគយល់ អត់ឱនដែលលោកទទួលពីការអប់រំនៅព្រះសហគមន៍កាតូលិក គួបផ្សំនឹងការខិតខំប្រឹងប្រែងខ្លួនឯង និងការទទួលអប់រំនៅតាមសាកលវិទ្យាល័យ គឺជាប្រភពដែលលោកទទួលបានការងារមួយពិតប្រាកដ។

លោកបានបន្តថា នៅពេលនេះនៅក្នុងការងារក៏ដូចជានៅក្នុងគ្រួសារ គឺលោករមែងយកអ្វីដែលជា ចំណេះដឹងដែលទទួលបានការអប់រំពីព្រះសហគមន៍មកធ្វើការដោះស្រាយជាបន្តបន្ទាប់។

លោកបានបញ្ជាក់ថា "គ្មានអ្វីដែលមិនអាចដោះស្រាយបាន ជាមួយនឹងក្តីស្រលាញ់នោះទេ"។

ជុំវិញជំនឿសាសនានេះដែរលោកស្រី ឡៃ មករា ជានាយិការងនៃវិទ្យាល័យសន្តហ្វេង់ស័រ មានប្រសាសន៍ថា នៅកម្ពុជាគឺមិនមានការរើសអើងទេ។

លោកស្រី បានបន្តថា ជាទូទៅនៅក្នុងសង្គមកម្ពុជាភាគច្រើន គេស្គាល់គ្រីស្តសាសនា ដោយហៅថា យេស៊ូ ប៉ុន្តែជាទូទៅគឺយើងមិនដែលមានបញ្ហានឹងគ្នាឡើយ។

លោកស្រី បានផ្តល់សក្ខីភាពថា លោកស្រី បានទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទ ដោយសារតែគ្រីស្តសាសនា ជាទូទៅ គឺណែនាំ និងអប់រំមនុស្សឲ្យ រៀនបើកចិត្តបើកគំនិតទទួលមនុស្សគ្រប់ឋានៈ ចេះចែករំលែកហើយនិងការលះបង់ជាពិសេសគឺ ការកោតស្ញប់ស្ញែង នឹងការលះបង់របស់អ្នកស្ម័គ្រចិត្ត លោកបូជាចារ្យ បងប្រុស បងស្រី ដែលតែងតែជួយមនុស្សគ្រប់ឋានៈដោយមិនចង់បានអ្វីតបស្នងវិញ។

*អរិយបុត្រ*

# ចង់ក្លាយជាគ្រីស្តបរិស័ទ ទាល់តែឆ្លងកាត់ការអប់រំជំនឿ

ការសម្រេចចិត្តយកមាគ៌ាជីវិតតាមគោលលទ្ធិនៃព្រះសហគមន៍កាតូលិក វាមិនមែនជារឿងដែលងាយស្រួល ពោលគឺត្រូវតែឆ្លងកាត់ការអប់រំជំនឿមួយដ៏តឹងរ៉ឹង។ នេះបើតាមសំដី លោកបណ្ឌិត សំ ៉ានី ប្រធានវិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យបាត់ដំបង។

លោកបណ្ឌិតបានមានប្រសាសន៍ថា សម្រាប់លោកនៅមុនពេលទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីក្លាយជាគ្រីស្តបរិស័ទមួយរូប គឺលោកបានទទួលការអប់រំជំនឿប្រមាណជា៥ឆ្នាំ។

លោកបានមានប្រសាសន៍ថា នៅក្នុងដំណាក់កាលនេះ គឺយើងបានទទួលការបង្រៀនពីគោលលទ្ធិទូទៅរបស់ព្រះសហគមន៍កាតូលិក និងចំណេះដឹងទូទៅព្រមទាំងមានពេលគ្រប់គ្រាន់ នៅក្នុងការរិះគិត ពិចារណា និង ឆ្លងកាត់ដំណាក់បញ្ជាក់ជាបន្តបន្ទាប់ ។

លោកបានបន្តថា ឆ្លងតាមការបណ្តុះបណ្តាលនេះ មកដល់ពេលបច្ចុប្បន្នសារសំខាន់ ដែលលោកបានទទួលការអប់រំតាមគោលលទ្ធិព្រះសហគមន៍កាតូលិក គឺមានបីគឺសេចក្តីស្រលាញ់ ភាពស្មោះត្រង់ និង ទំនួលខុសត្រូវ។

លោកបញ្ជាក់ថា "ជាមួយនឹងពាក្យបីម៉ាត់នេះ ខ្ញុំតែងតែទទួលជោគជ័យនៅក្នុងការងារ ការសិក្សា ជាបន្តបន្ទាប់"។

លោក សុខ ពង្សាមេត្រី ជាប្រធានគម្រោងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យាមួយរូបបានឲ្យដឹងថា សម្រាប់លោកគឺដូចគ្នាទោះបីជាលោកមានម្តាយជាគ្រីស្តបរិស័ទហើយក៏ដោយ។

លោកបានបន្តថា ជាគ្រីស្តបរិស័ទម្នាក់ គឺតែងតែទទួលការអប់រំសំខាន់ គឺអត់ឱន មេត្តាករុណា និងក្តីស្រលាញ់។

លោកបានបន្តថា ដោយសារតែគោលការណ៍ទាំងនេះ ទើបគ្រប់ការងារ គ្រប់បញ្ហានៅក្នុងជីវិត របស់ខ្ញុំតែងតែយល់ថា មានពន្លឺសម្រាប់ដោះស្រាយជានិច្ច។

# ប្រមុខរដ្ឋាភិបាលៈ កម្ពុជា ជាសង្គមនៃសុខដុមនីយកម្មសាសនា

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ កាលពីថ្ងៃទី ១៤ខែ ធ្នូឆ្នាំ២០១៥ ថា កម្ពុជាជាសង្គមនៃសុដុមនីយកម្មសាសនា ហើយបានអំពាវនាវឲ្យប្រជាពលរដ្ឋបន្តពូនជ្រុំសុខដុមនីយកម្មសាសនាបន្តទៀត ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា កម្ពុជាជាប្រទេសមួយដែលមានសាសនាច្រើននៅក្នុងតំបន់ដែរ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ កម្ពុជានៅតែអាចរក្សាបាននូវសុខដុមនីយកម្មសាសនាជារៀងរហូតមក ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍បញ្ជាក់ថា "ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ មានរដ្ឋធម្មនុញ្ញចែងច្បាស់លាស់ ប៉ុន្តែពុំមានការរើសអើងឬជម្លោះសាសនាណាមួយកើតឡើងឡើយ"។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា គ្រប់សាសនាគឺ គោរព ប្រណិប័តន៍រៀងៗខ្លួន ប៉ុន្តែ គ្រប់សាសនា គឺផ្សព្វផ្សាយតែអំពើល្អ និងជំរុញការអប់រំឲ្យមនុស្សធ្វើអំពើល្អទាំងអស់គ្នា។

សម្តេចក៏បានអំពាវនាវ ឲ្យគ្រប់ក្រុមសាសនាទាំងអស់បន្តសុខដុមនីយកម្មនេះបន្តទៀត។

# ទីទាល់និងភាពទុរគតជាប្រភពនៃរបរសុំទាន



*ការសុំទានបានក្លាយជារបរមួយសម្រាប់ចិញ្ចឹមជីវិត ។ រូបថតដោយ៖ វាសនា*

តាមស្តុប តាមផ្សារ តាមរមណីដ្ឋាន តាមកន្លែងភោជនីដ្ឋាន នឹងតាមដង ផ្លូវមួយចំនួន នៅក្នុងរាជធានីបញ្ហា សុំទាន នៅតែជាបញ្ហាប្រឈមមុខមួយ ទោះបីជាបញ្ហានេះ វាកើតមានឡើងជាយូរមក ហើយក៏ដោយ។

ទិដ្ឋភាពវេទនា និងទុរគតរបស់បណ្តាអ្នកសុំទាន នៅតាមទីកន្លែងទាំងនោះ គឺនៅតែបន្តលងនៅក្នុងអារម្មណ៍ ប្រជាពលរដ្ឋ អ្នកទេសចរណ៍ និងសាធារណៈជននានានៅឡើយ មិនថាតែនៅតាមរាជធានី តាមខេត្ត តាមទីប្រជុំជនឡើយ បើទោះបីជានៅពេលនេះ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា បានអះអាងថា នៅពេលថ្មីៗនេះថា បានរំដោះខ្លួនចេញពីប្រទេសក្រីក្រ ដែលមានចំណូលទាប មកជាប្រទេសដែលមានចំណូលមធ្យមកំរិតទាបក៏ដោយ។

៉ា សួន ជាស្ត្រីទុរគតជនមួយរូប ដែលកំពុងតែបីកូន និងដឹកដៃកូនស្រីអាយុប្រហែលជា ៤ឆ្នាំ ដើរសុំទាននៅស្តុបបូកគោ កាលពីវេលាម៉ោងប្រមាណជា៧:៣០ កាលពីថ្ងៃទី១៣ ខែធ្នូ កន្លងទៅនេះបានឲ្យដឹងថា គ្មាននរណាកើតមកចង់ដើរសុំទានដូច្នេះទេ ប៉ុន្តែមកពីវាអត់ក៏ចេះតែដើរទៅ។

សួន បានឲ្យដឹងថា នាងក្លាយជាស្ត្រីដើរសុំទាននេះ ទើបតែប្រមាណជា ៣ខែប៉ុណ្ណោះ ក្រោយពេលដែលស្វាមីរបស់នាង ដែលទៅធ្វើការនៅថៃលែងមានដំណឹង លែងផ្ញើរលុយឲ្យ ទើបដាច់ចិត្តដឹកដៃកូនប្រកបរបរបែបនេះ។

សួន បានអះអាងថា នាងគ្មានគោលដៅទេ ក្រោយពីសម្រេចចិត្តចាកចេញពីស្រុកកំណើតនៅខេត្តព្រៃវែង ទៅតាមរកដំណឹងប្តីនៅប៉ោយប៉ែត ហើយត្រឡប់មកវិញអស់លុយ អស់កាក់ ក៏ទីទាល់នៅដើរសុំទានគេបែបនេះ។

សួន បានបញ្ជាក់ថា "ខ្ញុំមិនចង់ទេ ប៉ុន្តែវាទាល់ក៏សម្រេចចិត្ត ធ្វើបែបនេះទៅ ហើយសព្វថ្ងៃគ្មានគោលដៅទេ ដើរដល់ទីណាសុំគេនៅទីនោះ យប់ក៏ដេកជួនកាលតាមមុខផ្ទះគេ ជួនតាមមុខហាង ជួនតាមវត្ត ជួនសាលាសំណាក់ ជួនតាមផ្សារ"។

សួន បានបន្តទៀតថា ការរស់នៅហូបចុកនៅពេលនេះ គឺអាស្រ័យដោយការដើរសុំទានពីគេ ដោយបានលុយកាក់បន្តិចបន្តួច មួយថ្ងៃមួយម៉ឺន ទៅ២ម៉ឺនរៀល គ្រាន់ទិញបាយឲ្យកូនហូប ។

នេះគឺជាសំដីរបស់ស្ត្រី ទុរគតជនមួយរូប ប៉ុន្តែនៅក្នុងរាជធានីភ្នំពេញ នាពេលសព្វថ្ងៃនេះ មិនមែនមានតែ ស្រី ៉ា សួននេះតែមួយនោះទេ គឺមានជាច្រើនរយនាក់ ដោយដើរតត្រាច់ ដើម្បីប្រកបរបរនេះទាំងចាស់ ទាំងក្មេង ទាំងស្រី ទាំងប្រុស ទាំងកុមារថែមទៀត ។

លោក ជរ សុខរដ្ឋា ហៅអាត្រក ជាទុរគតជនមួយរូប ដែលកំពុងតែប្រកបរបរដើរសុំទាននេះមួយរូបដែរនោះ បានអះអាងថា វាអត់ជម្រើស ពីព្រោះតាំងពីធ្លាក់ខ្លួនពិការ ដោយសារតែសង្គ្រាមកាលពីឆ្នាំប្រហែលជា ១៩៩០។

លោកនិយាយទាំងទឹកមុខ ក្រៀមក្រំថា ជីវិតវាអត់កំណើត កើតមានជាកូនអ្នកក្រីក្រ នៅទល់ដែនអត់បានរៀនសូត្រ ក៏ទៅចូលធ្វើទាហាន ហើយក៏ធ្លាក់ខ្លួនពិការ។

នៅមុនពេលដែលពិការ លោកធ្លាប់មានគ្រួសារ មានប្រពន្ធ មានកូន មានស្រែ មានចំការនឹងធ្វើចិញ្ចឹមជីវិតនឹងគេដែរ ប៉ុន្តែវាអកុសល ជីវិតជួបបញ្ហាបែបនេះមិនដឹងធ្វើយ៉ាងម៉េច ។

លោកបាន រៀបរាប់អំពីជីវិតទុរគតជនរបស់ខ្លួនថា ក្រោយពេលដែលពិការ ទ្រព្យសម្បត្តិបន្តិចបន្តួច ក៏លក់មើលខ្លួនអស់ទៅ យូៗទៅប្រពន្ធក៏នាំកូនរត់ចោលលោកបាត់ទៅ ហើយតាមដំណឹងថា គេមានប្តីថ្មី ដូច្នេះលោកក៏ខូចចិត្តខ្មាស់គេលែងចូលស្រុករស់នៅអាស្រ័យនឹងទានពីគេ ទាំងខ្វាត់ព្រាត់តែឯងបែបនេះទៅ។

លោកបានបន្តថា លោកមិនចាំទេថាធ្លាក់ខ្លួនជាអ្នកសុំទានគេនេះ តាំងពីអង្កាល់ ប៉ុន្តែវាមិនឆាប់ណាស់ដែរ។ លោកបានបន្តថា លោកមិនមែនសុំទានគេ តែនៅភ្នំពេញទេកន្លែងណាក៏ លោកធ្លាប់ទៅដែរ ។

លោកបានបញ្ជាក់ថា "ជីវិតឥចឹង តែដើរទៅយប់ណា ដេកនៅកន្លែងហ្នឹងទៅ"។

ស្ត្រីទុរគត់ជនម្នាក់ទៀតឈ្មោះ នាង ស៊ីចាន់ បានឲ្យដឹងថា នាងគឺជាក្មេងកំព្រា ហើយជីវិតក៏ខ្វាត់ព្រាត់បែប នេះតាំងពីក្មេងមក ។

ស្ត្រីទុរគតជនរូបនេះ បានបន្តថា តាំងពីកុមារមក ដល់ពេលនេះ គឺជីវិតនាងរស់នៅតែលើចិញ្ចឹមផ្លូវ ដោយរបរនេះ ប៉ុន្តែប៉ុន្មានឆ្នាំមុន ក៏មានឱកាសភ្លឺស្វាងនឹងគេ ក្រោយពីស្គាល់បុរសម្នាក់នៅកំពង់សោម (ខេត្តព្រះសីហនុ) ក៏រស់នៅជាមួយគ្នាបានកូនពីរ ក្រោយមកក៏បាត់ដំណឹង ក្រោយបុរសនោះចុះទូកថាទៅធ្វើការនៅកោះកុង ទើប បានជីវិតត្រឡប់មករកជីវិតដើមបែបនេះវិញ។

ស្ត្រីរូបនោះ បានបន្តទៀតថា នាង និងកូនធ្លាប់បាន គេប្រមូលទៅដាក់នៅមណ្ឌលស្តានិតិសម្បទា ព្រៃស្ពឺជាបន្តបន្ទាប់ ហើយក៏ធ្លាប់ត្រូវបានអង្គការហៅទៅរៀនអីហ្នឹងគេដែរ ប៉ុន្តែវាអត់កំណើតរៀនអីក៏មិនចេះ ក៏នៅតែគេច មិនផុតពីរបរនេះដដែល។

ស៊ីចាន់ បានឲ្យដឹងថា "នៅមណ្ឌលគឺដូចជាមិនអីទេ គ្រាន់តែអត់សេរីភាព គេបង្រៀននេះបង្រៀននោះច្រើនតែខ្ញុំវាទាល់ ដោយសារអត់នរណាមើលកូនផង អត់ទន់ផង ឥចឹងហើយ ពេលចេញពីមណ្ឌល គឺនៅតែសុំទាន បែបនេះ"។

ដើម្បីលុបបំបាត់បញ្ហាទុរគតជននេះ កាលពីពេលថ្មីៗនេះ លោក វង សូត្រ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធាន គណៈកម្មាធិការជាតិ ដោះស្រាយបញ្ហាជនអនាថា ស្នើឲ្យក្រុមបច្ចេកទេសអន្តរក្រសួង ដោះស្រាយឲ្យបានលឿនបំផុត សម្រាប់ជនវិកលចរិត និងជនអនាថា នៅក្នុងប្រទេសកម្ពុជា។

លោក វង សូត បានលើកឡើងថា សម្រាប់ការដោះស្រាយ ជនវិកលចរិត និងជនអនាថានេះ ក្រសួងបានកសាងលិខិតដ្ឋានគតិយុត្តិ និងបានកំណត់ជនអនាថា រួមសហការជាមួយអង្គការដៃគូមួយចំនួនផងដែរ ក្នុងការដោះស្រាយជនអនាថានៅកម្ពុជានេះ។

យោងទៅតាមស្ថិតិ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានឲ្យដឹងថា ជនអនាថាសរុបមានចំនួនជាង៣ពាន់នាក់ ស្រីជាង១ពាន់នាក់ និងកុមារជាង៤រយនាក់។ ជនអនាថាក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ មានចំនួនជិត២រយនាក់ ជនអនាថានៅមជ្ឈមណ្ឌលអង្គការ មានចំនួនជាង២ពាន់នាក់ និងជនអនាថានៅតាមសហគមន៍មានចំនួនជាង១ពាន់នាក់៕

*ដោយអរិយបុត្រ*

# សពលោកអភិបាលអេមីល ដេតម្បបញ្ចុះនៅស្រុកខ្មែរ



*សពអភិបាលអេមីល ត្រូវបានបញ្ចុះនៅក្នុងចេតិយព្រះវិហារសន្តយ៉ូសែប (ផ្សារតូច)។ រូបថតដោយ៖ សហការី*

"បើទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយក៏ខ្ញុំមិនចាកចេញពីប្រទេសកម្ពុជាឡើយ" នេះគឺជាសម្ដីរបស់លោកអភិបាលអេមីល ដេតម្ប ជាអតីតអភិបាលនៅក្នុងភូមិភាគភ្នំពេញ ដែលលោកតែងតែពោលពាក្យនេះជារឿយៗកាលលោកនៅមានជីវិត។

នៅទីបំផុតលោកអភិបាលវ័យ៨១ឆ្នាំ លោក អេមីល ដេតម្ប ជាជនជាតិបារាំង បានផុតរលត់ជីវិតនៅលើទឹកដីកម្ពុជាដូចក្តីប្រាថ្នារបស់លោកមែន។ ហើយការបាត់បង់ជីវិតរបស់លោកធ្វើអោយគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាក្តុកក្តួលជាខ្លាំងចំពោះការសំរេចចិត្តបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជាលុះអស់សង្ខារ។

ថ្លែងនៅពេលធម្មទេសនា ក្នុងបុណ្យសពរបស់លោកអភិបាលអេមីល ដេតម្ប នៅចំពោះមុខគ្រីស្តបរិស័ទទាំងបីភូមិភាគរាប់ពាន់នាក់ លោកអភិបាលអូលីវីយេ ផ្មឺតអីស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា ៖ នៅថ្ងៃនេះ គឺជាពេលវេលាចុងក្រោយមួយដែលយើងទាំងអស់គ្នារួមគ្នាជូនដំណើរលា លោកអភិបាល អេមីល ដើម្បីឲ្យលោកអភិបាលបានទៅរួមរស់ជាមួយនឹងព្រះជាម្ចាស់នៅស្ថានបរមសុខ។ លោកអូលីវីយេបន្តទៀតថា ៖ ចាប់តាំងពីខ្ញុំបានមកដល់ប្រទេសកម្ពុជាដំបូង និងរស់នៅក្រោមការមើលថែ របស់លោកអភិបាលអេមីល ដេតម្ប គឺខ្ញុំតែងតែលឺពាក្យអធិដ្ឋានរបស់លោកថា ៖ "ឱព្រះបិតាអើយ! ខ្ញុំលះបង់ចោលអ្វីៗទាំងអស់ខ្ញុំថ្វាយទៅព្រះបិតា សូមធ្វើតាមព្រះហឫទ័យព្រះអង្គចុះ អ្វីៗទាំងអស់ដែលព្រះបិត្តាធ្វើចំពោះខ្ញុំ ខ្ញុំថ្លែងអំណរគុណទៅព្រះបិតា ខ្ញុំបានត្រៀមជានិច្ចសម្រាប់ព្រះបិតា ខ្ញុំទទួលអ្វីៗទាំងអស់ពីព្រះវបិតា។"

ក្នុងនោះលោកអភិបាលអូលីវីយេ ក៏បានលើកឡើងនូវ២ចំនុចសំខាន់ៗ ដែលទាក់ទង និងជីវិតរបស់លោកអភិបាលអេមីលគឺ ជីវិតរបស់លោកអភិបាលដ៏ជាទីស្រលាញ់ និងជីវិតរបស់លោកជាជីវិតដែលបានផ្ញើទាំងស្រុងទៅព្រះជាម្ចាស់ទៅលើមនុស្សលោក ចំពោះការអធិដ្ឋាននិងនៅក្នុងការបម្រើ។

លោកអូលីវីយេបានបន្ថែមទៀតថា៖ "ជីវិតរបស់លោកអេមីល គឺជាបូជាចារ្យជាលោកអភិបាល និងជាអ្នកគង្វាលដ៏សប្បុរសម្នាក់ ហើយពិតជាមានអត្ថន័យលើសពីអ្វីៗទាំងអស់ ដែលលោកសុខចិត្តបូជាជីវិតក្នុងព្រះសហគមន៍នៅប្រទេសកម្ពុជា ព្រោះថាទោះជានៅសល់ដង្ហើមចុងក្រោយក៏លោកអភិបាលនៅជាមួយព្រះជាម្ចាស់រហូតផុតជីវិតទៅ។ ដោយហេតុនេះចាប់ពីពេលនេះតទៅខ្ញុំ(លោកអូវីយេ) និងបន្តអ្វីៗទាំងអស់ពីលោកអភិបាលអេមីល ហើយយើងរួមគ្នាប្រមូលស្រូវគ្រប់ទីកន្លែងដែលលោកអភិបាលអេមីលបានសាបព្រោះ"។

លោកអូលីវីយេបន្តទៀតថា ៖ រហូតមកដល់ពេលនេះ ខ្ញុំមានតែពាក្យអរគុណខ្លាំងបំផុតនៅអ្វីៗគ្រប់យ៉ាង ដែលគ្រូគង្វាលដ៏សប្បុរសរូបនេះបានលះបង់ និងផ្តល់ក្តីស្រលាញ់របស់លោកឲ្យយើងគ្រប់គ្នា ជាពិសេសបងប្អូននៅប្រទេសកម្ពុជា។

នៅក្នុងពិធីបុណ្យសពនោះផងដែរអ្នកស្រី ឆ្នារ យូប្រាកដ ជាអ្នកមើលថែលោកអភិបាលអេមីល ផ្ទាល់បានរៀបរាប់ថា៖ "អ្វីមុនគេបង្អស់ គឺខ្ញុំចង់អរគុណព្រះជា-ម្ចាស់ដែលផ្តល់ឱកាសឲ្យខ្ញុំបានមើលថែរក្សាលោកអេមីល។" អ្នកស្រីបន្តថា៖ បទពិសោធន៍របស់អ្នកស្រីដែលបានរស់នៅជាមួយលោកអភិបាលកន្លងមក គឺអ្នកស្រីបានរៀនពីលោកអភិបាល អេមីល ច្រើនណាស់ ទាំងអត្តចរិត ភាពអត់ធ្មត់ និងជីវិតខាងវិញ្ញាណ ព្រោះជារៀងរាល់ថ្ងៃ អ្នកស្រីតែងតែចូលរួម ថ្វាយអភិបូជាជាមួយលោកអភិបាល និងអធិដ្ឋាន ទាំងនេះ ជាកាផ្តល់កិត្តិយសយ៉ាងធំធេងណាស់សម្រាប់ជីវិតរបស់អ្នកស្រី។ និយាយលាយឡំជាមួយទឹកភ្នែកផង អ្នកស្រីក៏បានបន្តទៀតថា ៖ នៅពេលដែលលោកមកដល់ប្រទេសកម្ពុជានៅក្នុងឆ្នាំ ១៩៨៩ដំបូងបំផុត គឺលោកជួយឲ្យយើងដឹងពីតួនាទីរបស់យើង ដែលជាគ្រីស្តបរិស័ទ ហើយលោកបានរៀបចំឲ្យមានក្រុម៣គឺ អប់រំជំនឿ សង្គហៈ និងពិធីបុណ្យដើម្បីជួយសម្រួលពិធីផ្សេងៗ ក្នុងព្រះសហគមន៍ ហើយលើសពីនោះលោកអភិបាល អេមីល ក៏បានបង្រៀនម្នាក់ៗឲ្យស្គាល់តួនាទីរបស់ខ្លួនក្នុងការលើកតម្កើងព្រះជាម្ចាស់។ អ្នកស្រីបន្តថា ៖ អ្នកស្រីនៅក្បែរមើលថែលោកអភិបាលជាប់ជានិច្ច តែអ្នកស្រីបានត្រៀមចិត្តរួចហើយថាអ្វីៗដែលកើតឡើងនៅពេលខាងមុខ ដូចជាពេលនេះលោកអភិបាលបានទទួលមរណភាព គឺសុទ្ធតែជាគម្រោងការណ៍របស់ព្រះជាម្ចាស់ឲ្យយើងម្នាក់ៗចេះត្រៀមខ្លួនជានិច្ច។

ចំណែកលោកគីមរតនា ជានាយកប្រត្តិប័ត្តអង្គការការីតាសកម្ពុជាបានថ្លែងសក្ខីភាពក្នុងពិធីបុណ្យនេះថា ៖ លោកស្គាល់លោកអភិបាល អេមីលដេតម្ប តាំងពីឆ្នា ១៩៩០។ ការស្គាល់នេះគឺតាមរយៈសកម្មភាពផ្សេងៗក្នុងព្រះសហគមន៍ តាមរយៈក្រុមយុវជន និងការធ្វើការនៅក្នុងអង្គការការីតាស់កម្ពុជា។ លោករតនាបន្តថា ៖ "ខ្ញុំសូមកោតសរសើរលោកអភិ-បាល ដោយស្មោះព្រោះលោកបានខិតខំគ្រប់បែបយ៉ាងរួមជាមួយគ្រីស្តបរិស័ទដែលនៅសេសសល់ពីសង្គ្រាម រហូតមានការទទួលស្គាល់ជាផ្លូវការអំពីព្រះសហគមន៍កាតូលិកនៅកម្ពុជា នៅថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៩០ នឹងជាការបើកអភិបូជាលើកដំបូងនៃថ្ងៃបុណ្យចម្លងនៅសាលមហោស្របចេនឡា"។ លោកបន្តថា៖"ខ្ញុំបានចូលរួមជាមួយលោកអភិបាលនៅក្នុងអង្គការការីតាស់កម្ពុជាដែលជាស្ថាប័នមួយរបស់ព្រះសហគមន៍ កាតូលិកដែលលោកអភិបាលអេមីល ស្រលាញ់ជាទីបំផុត។ លោកអភិបាល គឺជាប្រធានស្ថាបនិកនិងជាប្រធានរបស់អង្គការការីតាស់ លោកបានធ្វើកិច្ចការជាច្រើនជាមួយអង្គការការីតាសដូចជា ជួយអ្នកក្រីក្រ ស្រ្តីមេម៉ាយ ក្មេងកំព្រា និងអ្នកគ្មានទីពឹងដោយសេចក្តីមេត្តាករុណា។ លោកផ្តល់នូវគំរូជាច្រើនដល់អ្នកនៅជុំវិញខ្លួនផ្តល់កម្លាំងចិត្តនិងលើកទឹកចិត្តកូនចៅគ្រប់គ្នា ដោយយកព្រះជាម្ចាស់ជាទីពឹងជានិច្ច។

នាយកប្រត្តិប័ត្តនៃអង្គការការីតាសកម្ពុជារូបនេះបន្តទៀតថា៖ ខ្ញុំសូមចូលរួមរំលែកទុក្ខ និងស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតរបស់លោកអេមីល ហើយសូមលោកជួយអង្វរព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍កាតូលិកនៅ កម្ពុជាជាកន្លែងដែល លោកស្រលាញ់ឥតព្រំដែន។

លោកអភិបាលអេមីល ដេតម្ប តែងតែនិយាយកាលលោកនៅរស់ថា ៖ ខ្ញុំស្រលាញ់ប្រទេសកម្ពុជា ចង់បម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា ចង់រស់នៅប្រទេសកម្ពុជា និងចង់ស្លាបនៅក្នុងទឹកដីប្រទេសកម្ពុជា។

លោកអភិបាលអេមីល ប្រសូតនៅក្នុងឆ្នាំ១៩៣៥ និងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងឆ្នាំ១៩៦១។ លោកបានមកដល់ប្រទេសកម្ពុជាលើកទី១ក្នុងឆ្នាំ ១៩៦៤ ប៉ុន្តែដោយសារសង្គ្រាម លោកត្រូវខ្មែរក្រហមបណ្តេញចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥។ ឆ្នាំ១៩៨៩ លោកត្រលប់មកកម្ពុជាវិញ។ លោកទទួលអគ្គ-សញ្ញាតែងតាំងជាអភិបាលក្នុង១៩៩៧ និងជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ពីឆ្នាំ ២០០១-២០១០។ លោកបានទទួលមរណភាពនាថ្ងៃទី២៨ មករា ២០១៦ នៅវេលាម៉ោង១២:៣០ ហើយសពរបស់លោកបានបញ្ចុះ នៅព្រះវិហារសន្តយ៉ូសែបផ្សារតូចភ្នំពេញ នៅថ្ងៃទី៣០ មករា ២០១៦។ *ដោយ ស្រីម៉ាច*


"...ព្រះជាម្ចាស់ជាសេចក្ដីស្រលាញ់"
(១យហ ៤,៨ខ)
God is Love
(1jn 4,8)
1935
លោកអភិបាល
Bishop Emile











2016

អេមីល ដេតម្ប

le DESTOMBES









# ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញបើកទ្វារដ៏វិសុទ្ធ ឆ្នាំព្រះមហាករុណាទិគុណ



*គ្រីស្តបរិស័ទភូមិភាគភ្នំពេញ អធិដ្ឋាន នៅមុខទ្វារដ៏វិសុទ្ធ នៃមណ្ឌលសកម្មភាពភ្នំពេញថ្មី។ រូបថត៖ សុធារិទ្ធ*

គ្រីស្តបរិស័ទ ប្រមាណជិតមួយពាន់នាក់ បានចូលរួមយ៉ាងឱឡារឹកក្នុងកម្មវិធីបើកទ្វារដ៏វិសុទ្ធនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

ពិធីប្រកាសបើកទ្វារដ៏វិសុទ្ធនេះ ត្រូវបានប្រារព្ធធ្វើឡើងនៅមណ្ឌលសកម្មភាពភ្នំពេញថ្មីព្រះវិហារសន្តប៉ូល និងសន្តសិលាក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេ ដ្មឹតអឺស្លែរ និងបូជាចារ្យនៃព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញទាំងអស់កាលពីថ្ងៃទី១០ ធ្នូ ២០១៥ កន្លងទៅ។

ពិធីនេះ ត្រូវបានគ្រីស្តបរិស័ទនៅក្នុងព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញទាំងអស់ហៅថា ជាពិធីប្រកាសពីឆ្នាំព្រះមហាករុណាទិគុណសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះបិតាជាផ្លូវការ។

ក្នុងឱកាសបើកកម្មវិធីនេះលោកអភិបាល អូលីវីយេ បានប្រកាសជាឱឡារឹកពីគោលបំណងដែលសម្តេចប៉ាបហ្វ្រង់ស៊ីស្កូបាននឹកដល់ទុក្ខលំបាករបស់ពិភពលោក ដោយអញ្ជើញឲ្យ ព្រះសហគមន៍កាតូលិកទាំងអស់នៅលើពិភពលោក បើកទ្វារនៃព្រះមហាករុណាទិគុណ ដើម្បីសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះបិតានៅតាមមណ្ឌលសកម្មភាពរបស់ខ្លួននីមួយៗ ជាពិសេសព្រះសហគមន៍ មានឱកាសណែនាំគ្រីស្តបរិស័ទ តាមភូមិភាគផ្ទាល់មានសិទ្ធិទទួលការអនុគ្រោះពិសេសពីព្រះជាម្ចាស់ នៅក្នុងឆ្នាំ២០១៦ នេះ។

នៅក្នុងថ្ងៃនោះ គ្រីស្តបរិស័ទបានជួបជុំគ្នានៅមុខព្រះវិហារសន្តប៉ូល និងសន្តសិលាស្តាប់ការប្រកាសរបស់លោកអភិបាល និងហែចូលទៅក្លោងទ្វារដ៏វិសុទ្ធ។ លោកអភិបាលអូលីវីយេ បោនមានប្រសាសន៍ថា "ដោយព្រះពររបស់ព្រះជាម្ចាស់ ទ្វារនេះ ប្រៀបដូចទ្វារនៅវិសាលវិហារសន្តសិលានៅទីក្រុងរ៉ូម ហើយពេលយើងឆ្លងទ្វារនេះ គឺមានន័យថាយើងឆ្លងព្រះយេស៊ូគ្រីស្ត ដែលជាទ្វារទៅស្ថានបរមសុខ"។

ឆ្លៀតក្នុងឱកាសនេះ លោកអភិបាលក៏បានអប់រំនិងណែនាំគ្រីស្តបរិស័ទទាំងអស់តាមរយៈធម្មទេសនាដោយមានប្រសាសន៍ថា "ទ្វារដែលយើងបានដើរចូល ជាទ្វារសក្ការៈ ជាទ្វារដែល ព្រះយេស៊ូផ្ទាល់បានបើក ហើយរាល់ពេលយើងឆ្លងមានន័យថា យើងសុខចិត្តកែប្រែចិត្តគំនិត និងអធិដ្ឋានរួមជាមួយព្រះនាងម៉ារីដើម្បីស្គាល់ព្រះយេស៊ូកាន់តែច្បាស់"។

លោកអភិបាល បានមានប្រសាសន៍បន្តថា "យើង ជាស្នាព្រះហស្តដែលព្រះជាម្ចាស់ បានបង្កើតមក ហើយយើងទទួលការសង្គ្រោះដោយសារជំនឿរបស់យើង ដោយទទួលជីវិតថ្មី និងជាបុត្រធីតារបស់ព្រះជាម្ចាស់ និងមានព្រះយេស៊ូជាគំរូ ដូចនេះ យើងត្រូវធ្វើអំពើល្អ ដើម្បីបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់"។

លោកមានប្រសាសន៍បែបនេះដោយសង្កត់ធ្ងន់ថា "តាមរយៈគណៈកម្មការសង្គហៈ និងគ្រីស្តបរិស័ទ សូមនាំអ្នកក្រីក្រឲ្យចូលរួមក្នុងសង្គមយ៉ាងសកម្ម តាមរយៈសកម្មភាពធម៌មេត្តាករុណាទាំង៧ ដើម្បីកែប្រែចិត្តគំនិត និងឲ្យជំនឿរបស់យើងមានផលផ្កាផ្លែ ព្រមជាមួយនិងសេចក្តីស្រឡាញ់"។

លោកបានជំរុញឲ្យគ្រីស្តបរិស័ទទាំងអស់ឲ្យយកចិត្តទុកដាក់ក្នុងការសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងធ្វើបូជនីយកិច្ច ដោយចាប់ផ្តើមចូលតាមក្លោងទ្វារដ៏វិសុទ្ធនេះ ទៅកាន់ព្រះវិហារសន្តយ៉ូសែបផ្សារតូច និងបញ្ចប់នៅព្រះវិហារព្រះមាតានៃសន្តិភាព(អរិយក្សត្រ) ដើម្បីអធិដ្ឋានទទួលអគ្គសញ្ញានានា ជាពិសេសអគ្គសញ្ញាសម្រុះសម្រួល ដើម្បីទទួលបាននូវការអនុគ្រោះពិសេសពីព្រះជាម្ចាស់។

*ដោយ៖ដាលីស*



# ឈាមមរណសាក្សីជាគ្រាប់ពូជ នៃជំនឿរបស់គ្រីស្តបរិស័ទ

លោក អូលីវីយេ ដ្មឹស្លែអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពញ បានជំរុញឲ្យ គ្រីស្តបរិស័ទទាំងអស់យកចិត្តទុកដាក់អធិដ្ឋាន និងរិះគិតអំពីការលះបង់ និងសកម្មភាពរបស់បណ្តាមរណសាក្សី ដើម្បីកសាងជំនឿឲ្យកាន់តែរឹងមាំ។

ថ្លែងនៅក្នុងពិធីបើក បន្ទប់អធិដ្ឋានសម្រាប់មរណៈសាក្សី នៅប្រទេសកម្ពុជាក្នុងឆ្នាំព្រះមហាករុណាទិគុណសម្តែងព្រះហឫទ័យប្រណីសន្តោស នៅព្រះវិហារសន្តយ៉ូសែបផ្សារតូចកាលពីពេលថ្មីៗនេះ នៅចំពោះមុខគ្រីស្តបរិស័ទប្រមាណជាង ៥០០នាក់ លោកអភិបាលអូលីវីយេបានមានប្រសាសន៍ថា៖ នៅពេលយើងបានឃើញបន្ទប់អធិដ្ឋាន សម្រាប់មរណៈសាក្សី នៅក្នុងព្រះវិហារសន្តយ៉ូសែបផ្សារតូចនេះ គឺជាកន្លែងទីពីរសម្រាប់ (តទំព័រ២១)

(តពីទំព័រ២០) ឆ្នាំមហាករុណាទិគុណក្នុងភូមិភាគភ្នំពេញ ហើយធ្វើឲ្យយើងនឹកឃើញដល់កន្លែងទីមួយ គឺនៅតាំងគោក។

លោកអភិបាលបានបន្តថា ចំណែកបន្ទប់ដែលបានរៀបចំស្រដៀងគ្នាទៅនឹងកន្លែងតាំងគោក គឺដើម្បីអោយក្នុងឆ្នាំមហាករុណាទិគុណនេះ យើងនឹកឃើញដល់មរណៈសាក្សីដែលបានបូជាជីវិតនៅសម័យប៉ុលពត។ លោកបានថ្លែងបញ្ជាក់ថា ៖ នេះវាគ្រាន់តែជានិមិត្តរូប តែយើងត្រូវចងចាំជានិច្ចនូវដំណក់ឈាមរបស់មរណៈសាក្សីទាំងអស់ទៅនឹងជំនឿរបស់យើងរាល់គ្នារួមមានលោកឆ្មារសាឡាស់ និងលោកសាឡឹម និងសហការីផ្សេងទៀតជាដើម ដែលបានបាត់បង់ជីវិតព្រោះតែជំនឿ។

លោកអភិបាលបានបន្ថែមថា៖នៅក្នុងពេលវេលាគឺណែនាំព្រះសហគមន៍តាមរយៈមរណសាក្សី ដើម្បីអោយយើងបានទទួលជីវិតថ្មី និងធ្វើបទពិសោធនដើម្បីមហាករុណាទិគុណ និងអំពីរបៀបដែលព្រះជាម្ចាស់ស្រលាញ់យើង ព្រោះថាមរណសាក្សីហ៊ានលះបង់ជីវិត គឺដោយសារពួកគាត់គិតថាព្រះយេស៊ូស្រលាញ់ពួកគាត់ ហើយតាមរយៈព្រះបន្ទូលមួយគឺ "កុំខ្លាចអី! ខ្ញុំទេតើដែលធ្វើដំណើរជាមួយអ្នក" ហេតុនេះ ទើបមរណសាក្សីស៊ូប្តូរជីវិត ដោយសារតែសេចក្តីស្រលាញ់របស់ព្រះយេស៊ូ ព្រោះព្រះយេស៊ូបានយាងចូលយ៉ាងជ្រៅក្នុងជីវិតរបស់ពួកគាត់។

លោកអភិបាលមានប្រសាសន៍បន្ថែមទៀតថា ដោយហេតុនេះ មរណសាក្សីគឺជាបទពិសោធន៍យ៉ាងច្បាស់មួយដើម្បីឲ្យយើងជាគ្រីស្តបរិស័ទយល់ច្បាស់អំពីព្រះហឫទ័យស្រលាញ់របស់ព្រះយេស៊ូនឹងណែនាំអោយយើងមានកម្លាំងថ្មីដើម្បីបន្តប្រកាសដំណឹងល្អ ចែករំលែកសេចក្តីស្រលាញ់បង្កើតភាពយុត្តិធម៌និងណែនាំឲ្យអ្នកដទៃអាចរកឃើញសុភមង្គលតាមរយៈព្រះយេស៊ូដែលជាជីវិត។

លោកបូជាចារ្យ រឿង ផ័ត្រសិរី ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កាតូលិកផ្សារតូចនិងជាអ្នករៀបចំសំណុំឯកសារមរណសាក្សី នៅប្រទេសកម្ពុជាផងនោះបានប្រាប់អោយដឹងថា៖លោកមានអារម្មណ៍រំភើបជាខ្លាំង នៅពេលដែលបានរៀបចំកន្លែងអធិដ្ឋានសម្រាប់មរណសាក្សីរួចរាល់។

លោកបន្តថា៖ នៅពេលកំពុងរៀបចំយើងបានអធិដ្ឋានទៅដល់មរណសាក្សីទាំងអស់ថា៖ សូមអោយបន្ទប់នេះបានក្លាយទៅជាកន្លែងសក្ខីភាពនិងជាកន្លែងមួយសម្រាប់អធិដ្ឋានផងដែរ ព្រោះថាតាមការស្វែងរកឈ្មោះមរណសាក្សីនេះ គឺយើងបានទទួលទិន្នន័យពីបងប្អូនជាច្រើនដែលនៅរស់រានមានជីវិត និងដឹងហេតុការណ៍ខ្លះៗពីសក្ខីភាពរបស់បងប្អូនទាំងនោះ។

លោកបូជាចារ្យបានបន្ថែមថា៖ ការរៀបចំនេះបើទោះបីជាវាមិនដូចពិតៗនៅក្នុងសម័យនោះតែនេះ ជារូបភាពនិងការនឹកស្រមៃរបស់យើងថាតើក្នុងសម័យនោះមានហេតុការណ៍អ្វីខ្លះ? ហើយគ្រីស្តបរិស័ទរបស់យើងរស់នៅយ៉ាងណា? ហេតុនេះសូមយើងរួមគ្នាដើម្បីអធិដ្ឋានអង្វរព្រះជាម្ចាស់រួមជាមួយ និងមរណសាក្សីទាំងអស់ ដើម្បីអោយយើងតស៊ូដើម្បីជំនឿរបស់យើង តាមរយៈស្លាកស្នាមដែលសល់ពីមរណសាក្សី។

អ្នកស្រី ឆ្មារ ប្រកប ត្រូវជាប្អូនស្រីបង្កើតរបស់លោកអភិបាលឆ្មារ សាឡាស់ បានមានប្រសាសន៍ថា រឿងរ៉ាវបានកន្លងផុតទៅជាយូរមកហើយ តែការចងចាំនៅតែជិតជាមក្នុងដួងចិត្តដែលពោរពេញទៅដោយការឈឺចាប់អស់មួយជីវិតក៏មិនបាត់ដែរ។ អ្នកស្រីបញ្ជាក់ថា គ្រប់ពេលដែលនិយាយអំពីមរណសាក្សី គឺខ្ញុំហូរទឹកភ្នែកមករហូតព្រោះថា ពួកគាត់សុខចិត្តស្លាប់ព្រោះតែជំនឿ ទោះបីមានសង្គ្រាមលំបាកយ៉ាងណាក៏មិនភ្លេចព្រះជាម្ចាស់ រួមគ្នា អធិដ្ឋាន ថ្វាយអភិបូជាស្រលាញ់ព្រះជាម្ចាស់លុះដល់ដង្ហើមចុងក្រោយ។

*ដោយ៖ រឿន ស្រីម៉ាច*

# គ្រីស្តបរិស័ទត្រូវបានជំរុញឲ្យបើកទ្វារទាំងបីនៃឆ្នាំព្រះមហាករុណាទិគុណ

លោក អូលីវីយេ ជ្មីតហាស្លែ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានក្រើនរំឭកនិងជំរុញឲ្យគ្រីស្តបរិស័ទប្រមាណជាមួយពាន់នាក់ នៅព្រះវិហារព្រះមាតានៃសន្តិភាព(អរិយក្សត្រ)ឲ្យបើកទ្វារទាំងបីនៃ ឆ្នាំមហាករុណាទិគុណ។

នៅក្នុងឱកាសអញ្ជើញទៅបើកទ្វារនៃក្តីសង្ឃឹមកាលពីថ្ងៃទី០១ មករា ២០១៦ លោកអភិបាល ក៏បានជំរុញឲ្យគ្រីស្តបរិស័ទឲ្យធ្វើបូជនីយេស៍។

លោកអភិបាលបានថ្លែងបញ្ជាក់ថា ក្នុងឆ្នាំព្រះមហាករុណាទិគុណ យើងត្រូវការបើកនៅក្នុងដួងចិត្តរបស់យើង នូវទ្វារបី គឺមានទ្វារនៃជំនឿ ទ្វារនៃសេចក្តីមេត្តាករុណា និងទ្វារនៃសេចក្តីសង្ឃឹមហើយទទួលអគ្គសញ្ញាលើកលែងទោស ដើម្បីទទួលការអនុគ្រោះពិសេស។

ស្របតាមអនុសាសន៍របស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ដែលបានទតឃើញបញ្ហានានាក្នុងពិភពលោក និងឲ្យយើងដែលជាគ្រីស្តបរិស័ទ មានសាមគ្គីភាពវាងគ្នា និងគ្នាហើយមានចិត្តមេត្តាករុណាដើម្បីបង្កើតសុខសន្តិភាព លោកអភិបាល អូលីវីយេ បានបង្ហាញឲ្យគ្រីស្តបរិស័ទយល់ថា ដើម្បីបានសុខសន្តិភាពនៅក្នុងពិភពលោក គឺយើងត្រូវមានចិត្តសាមគ្គីជួយគ្នាទៅវិញទៅមក គឺបើកកន្លែងឲ្យទូលាយដើម្បីជួយអ្នកដទៃ និងដើម្បីបង្ហាញមេត្តាករុណាតាមរបៀបដែលព្រះជាម្ចាស់មានធម៌មេត្តាករុណាសម្រាប់យើងម្នាក់ៗ។

លោកបានមានប្រសាសន៍ថា ទ្វារដែលបានបើកនៅក្នុងព្រះសហគមន៍ភូមិភាគភ្នំពេញទាំងបីកន្លែង គឺសុទ្ធតែសំខាន់ ហើយគ្រីស្តបរិស័ទត្រូវតែយល់ពីអត្ថន័យឲ្យបានច្បាស់លាស់។

លោកអភិបាលបានសង្កត់ធ្ងន់ថា ៖ សម្រាប់ទ្វារនៃជំនឿ ដែលយើងត្រូវបើកគឺដើម្បីឲ្យជំនឿរបស់យើងរឹងមាំ ហើយទទួលស្គាល់ថាព្រះយេស៊ូជាការសង្គ្រោះជាជីវិតរបស់យើង នេះជាព្រះជាម្ចាស់ដែលចាប់កំណើតជាមនុស្ស។

ដោយឡែកសម្រាប់ ទ្វារនៃក្តីមេត្តាករុណា ព្រះហឫទ័យប្រណីសន្តោស លោកអភិបាលបានពន្យល់ថា គឺជាអ្វីដែលគ្រីស្តបរិស័ទមានពេលពេញមួយឆ្នាំដើម្បីអនុវត្តតាមផ្លូវវិញ្ញាណ និងផ្លូវកាយដើម្បីឲ្យព្រះសហគមន៍របស់យើងមានពន្លឺអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់សម្រាប់បងប្អូនទាំងអស់។

រីឯទ្វារនៃសេចក្តីសង្ឃឹមវិញ លោកអភិបាលបានពន្យល់ថា ដោយសារគ្រីស្តបរិស័ទគឺជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម ហើយជំនឿរបស់យើងណែនាំឲ្យមានចិត្តធម៌មេត្តាករុណា ហេតុនេះយើងមានសេចក្តីសង្ឃឹមជានិច្ច ហើយអ្វីដែលពិភពលោកខ្វះ គឺសេចក្តីសង្ឃឹម ព្រោះខ្វះមេត្តាករុណា ដែលជាប្រភពមកពីយើងខ្វះជំនឿលើព្រះជាម្ចាស់។

លោកបន្តថា នៅក្នុងឆ្នាំមេត្តាករុណានេះ ព្រះជាម្ចាស់ដែលស្រឡាញ់យើងអញ្ជើញយើងឲ្យចេះស្រឡាញ់ លើកលែងទោសឲ្យគ្នាទៅវិញទៅមក ដោយទទួលសេចក្តីស្រឡាញ់ និងការលើកលែងទោសរបស់ព្រះអង្គនៅក្នុងជីវិតរបស់ពួកយើងផ្ទាល់។

លី សុវណ្ណា



# ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ប្រារព្ធពិធីបើកឆ្នាំព្រះមហាករុណាទិគុណ



*លោកអភិបាលគីគេ បើកទ្វារដ៏វិសុទ្ធនៃឆ្នាំព្រះមហាករុណាទិគុណ សម្តែងព្រះហឫទ័យប្រណីសន្តោស នៅបាត់ដំបង។ រូបថតៈ ឡុង សម្ផស្ស*

ជាមួយនឹងសម្លេងផៃយាំ ដែលបន្លឺឡើងនៅព្រះវិហារ ព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខស្ថិត ក្នុងភូមិរំចេក១ សង្កាត់រតនៈ ក្រុង និងខេត្តបាត់ដំបង នៃព្រះសហគមន៍ កាតូលិកភូមិភាគបាត់ដំបង កាលពីរសៀលថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ កន្លងទៅនេះ បានប្រារព្ធពិធីបើកទ្វារដ៏ វិសុទ្ធ ដែលជាការបើកឆ្នាំព្រះមហាករុណាទិគុណ សម្តែងព្រះហឫទ័យប្រណីសន្តោស។

ក្នុងពិធីនោះ មានការអញ្ជើញចូលរួមក្រោមអធិបតីភាពលោក អេនរីកេ ហ្វីការ៉េដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោកបូជាចារ្យ បងប្រុសបងស្រី រួមជាមួយបងប្អូនគ្រីស្តបរិស័ទ មកពីព្រះសហគមន៍នានាយ៉ាងច្រើនកុះករ ប្រមាណជាង ៥០០នាក់។

ពិធីនេះត្រូវបានរៀបចំឡើង ស្របគ្នាជាមួយនឹងពិធីផ្លូវការនៅឯព្រះវិហារសន្តបាស៊ីលីកា នៃបុរីវ៉ាទីកង់ ដែលប្រកាសបើកដោយសម្តេចប៉ាប ហ្វ្រង់ ស៊ីស្កូ រួមជាមួយនិងសម្តេចប៉ាបអេមេរីទូស បេណេឌិកទី១៦ ។

លោកអភិបាល បានមានប្រសាសន៍ថា នៅថ្ងៃនេះជាថ្ងៃបុណ្យយ៉ាងឧឡារិក ដែលរំឭក ដល់ព្រះនាងម៉ារីគ្មានជំពាក់បាបកម្ម។ លោកបានបន្តទៀតថា ចាប់ពីពេលនេះតទៅ សម្រាប់យើងជាគ្រីស្តបរិស័ទ ត្រូវយកចិត្តទុកដាក់សម្តែងមេត្តាករុណា ចំពោះអ្នកទន់ខ្សោយ អ្នក ដែលគ្មានទីពឹង អ្នកដែលត្រូវគេសង្កត់ សង្កិនជាពិសេស គឺស្ត្រីមេម៉ាយ ក្មេងកំព្រា អ្នកក្រីក្រទុគ៌ត ។

លោក គូតែត បានេណាល់ ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍តំបន់អង្គរ នឹងជាតំណាងពេញសិទ្ធិរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង បានមានប្រសាសន៍ថា យើងទាំងអស់គ្នា ដែលបានអញ្ជើញមកពីព្រះសហគមន៍នានា នៃព្រះសហគមន៍ ភូមិភាគបាត់ដំបង ដែលជួបជុំគ្នានៅ ព្រះវិហារបាត់ដំបងនាថ្ងៃនេះ គឺយើងរួមគ្នាធ្វើការអធិដ្ឋាន ដើម្បីសុំសុខសន្តិភាព សម្រាប់ពិភពលោកទាំងមូល សម្រាប់ប្រទេសកម្ពុជាយើង សម្រាប់សង្គមគ្រួសារយើង និងសម្រាប់ប្រជាជនខ្មែរយើងទាំងអស់នោះផង ។

លោកបានបន្តទៀតថា អត្ថន័យនៃទ្វារដ៏វិសុទ្ធ នៅពេលយើងនាំគ្នាចូលទ្វារដ៏វិសុទ្ធ នាំឲ្យយើងគិតដល់ព្រះយេស៊ូ គឺព្រះអង្គផ្ទាល់គឺជាទ្វារ ដែលបានបើកចំហរនូវព្រះហឫទ័យមេត្តាករុណា របស់ព្រះអង្គចំពោះមនុស្សទាំងអស់។ ទ្វារដ៏វិសុទ្ធ បើកចំហរ គឺមានន័យថា សូមឲ្យយើងជាគ្រីស្តបរិស័ទម្នាក់ៗ បើកចំហរបេះដូង ចំហរដួងចិត្តរបស់យើង ឲ្យចេះយកចិត្តទុដាក់ ចំពោះអ្នកឯទៀតៗ។ ក្នុងពេលនោះដែរ លោកតូតែត ក៏បានបង្ហាញនូវរូបភាពមួយចំនួន ដែលទាក់ទងទៅ និងឆ្នាំសម្តែងមេត្តាករុណា ការលើកលែងទោស ការជួយអ្នកដទៃ និងការយកចិត្តទុកដាក់ ចំពោះអ្នកជម្ងឺជាដើម។

លោកបានបញ្ជាក់ថា "យើងសូមទូលអង្វរព្រះជាម្ចាស់ សូមព្រះអង្គទ្រង់ព្រះមេត្តាបំភ្លឺចិត្តគំនិត ហើយជួយណែនាំ និងពង្រឹងជំនឿរបស់យើងខ្ញុំឲ្យបានរឹងមាំ។ សូមឲ្យយើងខ្ញុំបានចូលរួមក្នុងព្រះហឫទ័យ នៃមហាករុណាទិគុណប្រណីសន្តោសរបស់ព្រះអង្គនោះផង" ។

គួរបញ្ជាក់ថា នៅពេលចាប់ផ្តើមកម្មវិធីមានបន្ទរដោយក្រុមភ្លេងផៃយាំ រួមជាមួយ និងការរាំរបាំព្រាបស នៅជុំវិញសសរសន្តិភាព បន្ទាប់មកក៏មានការដង្ហែរក្បួន មកកាន់ខាងមុខក្លោង ទ្វារដ៏វិសុទ្ធ ហើយមានរាំរបាំជូនពរ និងការបង្ហោះប៉េងប៉ោងព្រមទាំងព្រលែងសត្វព្រាបផងដែរ។

ឆ្នាំនេះ គឺជាឆ្នាំនៃព្រះមហាករុណាទិគុណ សម្តែងព្រះហឫទ័យប្រណីសន្តោស ដែលត្រូវបានប្រកាសបើក ចាប់ពីថ្ងៃនេះតទៅ រហូតដល់ថ្ងៃបិទ គឺដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៦ខាងមុខ៕

*ដោយឡុង សម្ផស្ស*






# ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមប្រកាសបើកទ្វារឆ្នាំមេត្តាករុណានៅអ្នកលឿង

បន្ទាប់ពីមានការបើកទ្វារដ៏វិសុទ្ធនៃឆ្នាំមេត្តាករុណានៅព្រះសហគមន៍កាតូលិកទាំងពីរភូមិភាគគឺ បាត់ដំបង និងភ្នំពេញ រួចមកព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម កាលពីចុងខែមករា ឆ្នាំ២០១៥ ក៏បានប្រកាសបើកទ្វាដ៏វិសុទ្ធសម្រាប់ភូមិភាគនេះផងដែរ។

ពិធីបើកទ្វារដ៏វិសុទ្ធនៃឆ្នាំមេត្តាករុណាសម្រាប់ព្រះសហគមន៍កាតូលិកភូមិ ភាគកំពង់ចាមត្រូវបានប្រារព្ធធ្វើឡើង នៅព្រះសហគមន៍កាតូលិកអ្នកលឿងក្រោមអធិបតីយ្យភាពរបស់លោក អន់តូនីសាមីស៊ូសៃរាជ្យ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម ដោយមានការចូលរួម ពីសំណាក់ លោក បូជាចារ្យ បងស្រី រួមនិងគ្រីស្តបរិស័ទប្រមាណជិតមួយពាន់នាក់។

នៅក្នុងឱកាសនោះ លោក អភិបាល អន់តូនី បានមានប្រសាសន៍ថា នេះគឺជាពិធីដែល ចង់ណែនាំអោយយើងចេះបម្រើគ្នាទៅវិញទៅមក ចេះបន្ទាបខ្លួន កុំលើកតម្កើងខ្លួន លើសពីនេះ យើងក៏ត្រូវតែកែប្រែចិត្តគំនិត កុំមើលងាយអ្នកដទៃ។

លោកអភិបាលក៏បានអោយដឹងបន្ថែមទៀតថា នៅពេលយើងលើកដៃប្រណមសកម្មភាពនេះគឺ ជាការបន្ទាបខ្លួនមួយ ។

លោកបញ្ជាក់ជូនគ្រីស្តបរិស័ទបន្ថែមទៀតថា ឆ្នាំនេះគឺជាឆ្នាំមហាករុណាទិគុណ ដែលចេញសេចក្តីប្រកាសដោយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ហើយនៅប្រទេសកម្ពុជា ព្រះសហគមន៍កាតូលិកក៏បានប្រកាសបើកទ្វារដ៏វិសុទ្ធជាបន្តបន្ទាប់។

លោកបានបញ្ជាក់ថា "ទ្វារដ៏វិសុទ្ធនេះជាច្រកដែលគ្រីស្តបរិស័ទ យើងត្រូវដើរដើម្បីកែប្រែចិត្តគំនិត ឆ្ពោះទៅភាពមហាករុណាទិគុណតាមព្រះសហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់"។



*លោកអភិបាលអន់តូនី ប្រកាសបើកទ្វារឆ្នាំមេត្តាករុណានៅព្រះសហគមន៍អ្នកលឿង។ រូបថតដោយ៖*

លោកអភិបាល បានបន្ថែមទៀតថា ឆ្នាំមហាករុណាទិគុណនេះគឺជាឆ្នាំដែលត្រូវសូមអង្វរព្រះជាម្ចាស់អោយយើងចេះភាពមេត្តាករុណាចំពោះគ្នា។

លោក ឡាយ ប៉ូល ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍កាតូលិកអ្នកលឿង បានប្រាប់អោយដឹងថា មូលហេតុដែលព្រះសគមន៍កាតូលិកភូមិភាគកំពង់ចាមជ្រើសរើសយកព្រះសហគមន៍អ្នកលឿងដើម្បីប្រារព្ធពិធីបើកទ្វារដ៏វិសុទ្ធ គឺដោយសារតែមានសាសនទូតនៃទីក្រុងប៉ារីស បានបូជាជីវិតក្នុងសម័យសង្គ្រាមក្នុងអំឡុងឆ្នាំ១៩៧០ ចំនួន ៣អង្គ ហើយមូលហេតុមួយទៀត គឺដោយសារតែអ្នកលឿងនេះ គឺជាព្រះសហគមន៍ធំជាងគេនៅក្នុងភូមិភាគកំពង់ចាម។

លោកប៉ូលបានបន្តថា បន្ទាប់ពីការបើកទ្វារមហាករុណាទិគុណនេះរួចហើយ គ្រីស្តបរិស័ទក៏បានរិះគិតរួមគ្នាដូចជាមានការអធិដ្ឋាន និងមានកម្មវិធីបូជនីចរតាមព្រះសហគមន៍នានាក្នុងភូមិភាគតាមសេចក្តីប្រកាស់របស់សម្តេចប៉ាប។

ព្រះសហគមន៍ភូមិភាគកំពុងចាម ក្នុងឆ្នាំព្រះមហាកុរណាទិគុណនេះ នឹងមានកន្លែងបូជនីយចរចំនួន ៣កន្លែងគឺ ព្រះសហគមន៍អ្នកលឿង ព្រះសហគមន៍ក្តុល-លើ និងព្រះសហគមន៍ កោះរការ។

*ដោយ៖រឿន ស្រីម៉ាច*






# មរណសាក្សីនៅប្រទេសកម្ពុជា



*រូបថតតំណាង បន្តោងឈើឆ្កាងលោកអភិបាលឆ្មារ សាឡាស់ ត្រូវបានលាក់ក្នុងសំបុកមាន់នៅជំនាន់ប៉ុលពត។ រូបថត៖ឡុង សម្ពស្ស*

.......(តពីលេខមុន)

រីឯបងស្រីម៉ារីក្លែរដែលជាបងស្រីខ្មែរ ត្រូវខ្មែរក្រហមបៀតបៀន បង្ខំឲ្យបោះរូបសំណាក់ព្រះនាងម៉ារីចោល តែបងស្រីផ្ដល់សក្ខីភាព ជំនឿលើដួងចិត្តថាជំនឿមិនមែនលើរូបសំណាក់ទេ។

បងស្រីបង្ហាញជំនឿ ទោះបីត្រូវដកឯកសណ្ឋានបងស្រីចេញ ក៏នៅតែរស់នៅតាមរបៀបបព្វជិតាជានិច្ច។

មានគ្រហស្ថភាគច្រើន ដែលខ្មែរក្រហមសម្លាប់ នៅឆ្នាំដដែលនេះ នៅភូមិភាគភ្នំពេញ គ្រីស្តបរិស័ទភាគច្រើនមកពីភូមិព្រះមាតាមានដូចជា លោកបែរណាដូរម៉ម បុប្ផានី ដែលជាជាអ្នកលេងភ្លេងដ៏ល្បីនៅពេលនោះ។ លោកជួយ ព្រះវិហារលេងភ្លេងក្នុងពិធីបុណ្យ។ លោកយ៉ូសែប សំ គីមសាន ដែលជាអតីតកូនសិស្សលោកអភិបាល នៅអនុទេវវិទ្យាល័យផ្សារតូច ហើយក្រោយមកលោកចេញពីសាលា ទៅធ្វើជាទាហាន។ លោកសុខចិត្តផ្ញើជីវិតលើ ព្រះជាម្ចាស់នៅក្នុងស្រុកខ្មែរ ជាងរត់ទៅប្រទេសថៃ ទោះបីលោកមានឱកាសក៏ដោយ ម្យ៉ាងទៀត លោកស្រឡាញ់គ្រួសារលោកណាស់។ លោកវរសេនីយ៍ឯក គ្រួច សម្រេច។ លោកជាទាហាន និងជាគ្រីស្តបរិស័ទ ដែលជួយព្រះសហគមន៍នៅភូមិព្រះមាតា អ្នកខ្លះថាលោកហ៊ានការពារព្រះវិហារនៅពេល ស្រុកកំពុងស្នូកស្នាញ និងលោករក្សា ឌឺម៉ុងតេរ៉ូ ដែលជាអ្នកនាំភ្លេង និង លេងភ្លេងក្នុងព្រះវិហារ។ ពេលត្រូវជម្លៀសទៅខេត្តកំពង់ចាម លោកតែងតែធ្វើសញ្ញាឈើឆ្កាងដោយសម្ងាត់ ដើម្បីឲ្យគេស្គាល់ថាលោកជាគ្រីស្តបរិស័ទ។

លោកបង្ហាញជំនឿបែបនេះ ដើម្បីឲ្យគ្រីស្តបរិស័ទស្គាល់លោក។ នៅភូមិកំពង់គោ ខេត្តកំពង់ធំ បានបង្កើតមរណសាក្សីជាច្រើនដែលភាគច្រើន ជាគ្រហស្ថ ដូចជាលោក ជឹង ជុន ជាគ្រូអប់រំជំនឿ និងជួយព្រះសហគមន៍។ លោក ហ៊ាន ឆ្លើយតបសំណួរ ពីទាហានខ្មែរក្រហមថា គាត់ជាគ្រីស្តបរិស័ទ។ លោក យ៉ូសែប ម៉ម សារូ គឺជាគ្រូអប់រំជំនឿ។

លោកត្រូវទាហានខ្មែរក្រហម មើលងាយថា ទៅកាន់សាសនាបារាំង ហើយគាត់មិនព្រម បោះចោលជំនឿឡើយ។ លោកសិលា ចិន ញិល បានបង្ហាញចិត្តធម៌មេត្តារបស់ព្រះជាម្ចាស់ អប់រំកូនចៅ និងឲ្យអធិដ្ឋាន នៅពេលជួបឧបសគ្គ។

លោកផ្ដល់សក្ខីភាពថា លោកជាគ្រីស្តបរិស័ទ ហើយត្រូវខ្មែរក្រហមយកទៅសម្លាប់ជាមួយមនុស្សប្រុសៗក្នុងភូមិ។

លោកតាសិលា ពេញ ជា ហ៊ានឲ្យអ្នកភូមិ ចេះសម្រុះសម្រួល ជាមួយពួកខ្មែរក្រហម។ ពេលគេចាប់សួរសំណួរ លោកហ៊ានឆ្លើយថា លោកជាកាតូលិក។ លោកត្រូវបញ្ជូនទៅភូមិផ្សេង ដើម្បីសម្លាប់ជាមួយអ្នកភូមិឯទៀត។

នៅឆ្នាំ ១៩៧៦ គឺចូលឆ្នាំទីពីរ នៃរបប ប៉ុល ពត ប្រជាជនត្រូវជម្លៀសទៅធ្វើការតាមជនបទ។ ឆ្នាំនេះ មានអ្នកបម្រើរបស់ព្រះជាម្ចាស់ម្នាក់ បានស្លាប់ គឺបងស្រីអានតេរេស ស៊ុន ស៊ីរ៉ាវី។ បងស្រីស្រឡាញ់គ្រួសារណាស់ បានត្រឡប់មកពីស្រុកបារាំង ហើយត្រូវជម្លៀសទៅខេត្តកំពង់ឆ្នាំង។

បងស្រីត្រូវទម្លាក់រូបសំណាកព្រះ នាងម៉ារីក្នុងទន្លេ ដោយចិត្តសោកស្ដាយ។ តាមសាក្សីប្រាប់ថា បងស្រីត្រូវបង្ខំឲ្យរៀបការ ហើយស្លាប់ពេលសម្រាលកូន។

ឆ្នាំ ១៩៧៧ ប្រជាជនរាប់លានអ្នកបានស្លាប់ជាបន្តបន្ទាប់ ជាពិសេស មកពីត្រូវបង្ខំឲ្យធ្វើការ ខ្វះថ្នាំព្យាបាល ជំងឺ ការអត់ឃ្លានយ៉ាងខ្លាំង និងការគាបសង្កត់ពីកម្មាភិបាលខ្មែរក្រហម។ លោកទាំងបី បានជួបលោកអភិបាល ឆ្មារ សាឡាស់ លោកបូជាចារ្យឆ្មារ សាឡឹម លោកបូជាចារ្យទ្រឿង សាង សំរើន ក្រោយបានជម្លៀស ទៅភូមិតាំងគោក ក៏ត្រូវជួបការពិបាកជាច្រើន។

លោកលបថ្វាយអភិបូជា និងអធិដ្ឋានជាមួយគ្នា។ លោកទាំងបីស្ម័គ្រចូលក្រុមចល័តតំបន់ ដើម្បីស្វែងរក គ្រីស្តបរិស័ទ ដែលអាចសេសសល់។ លោកអភិបាលសាឡាស់ ត្រូវបង្ខំធ្វើការរហូតដល់ស្លាប់ រីឯលោកសាឡឹម និងលោកសំរើន ត្រូវយកទៅធ្វើការកន្លែង ផ្សេងនោះ គឺយកទៅសម្លាប់។

ក្រុមបព្វជិតដែលស្លាប់នៅឆ្នាំនេះ គឺបងប្រុសដាមីយ៉ាំង។ លោកជាគ្រូអប់រំជំនឿ និង ដឹកនាំកូនសិស្សល្អ។ មុនស្លាប់ លោកមិនខ្លាច សេចក្ដីស្លាប់ឡើយ ដោយលោកផ្ញើជីវិត ទៅព្រះជាម្ចាស់ទាំងស្រុង។

មានក្រុមបងស្រី ក្រុមឧបការគុណជាច្រើនបានស្លាប់ក្នុងឆ្នាំនេះ គឺបងស្រីកង់ឌីដ ង្វៀន ធីណាយ, បងស្រី សេសារីន ប៊ួយធីង៉ន, បងស្រីហ្គុសស្ដាវ វ៉ ធី ទ្រី។ បងស្រីទាំងបីនេះ ជាជនជាតិវៀតណាម ដែលសម្រេចចិត្ត មិនគេចខ្លួន ប៉ុន្តែ សុខចិត្តបន្តរស់នៅជាមួយប្រជាជន និងបងស្រីខ្មែរម្នាក់ ឈ្មោះ លីឌី នូ សាវ៉ាន់។

បងស្រីទាំងអស់ មានបច្ចេកទេសខាងឱសថ។ បងស្រីជួយអ្នកជំងឺជា ច្រើនតាមភូមិ ជាពិសេសនៅពេទ្យ យាយជីខេត្តបាត់ដំបង។ ពេលបងស្រី បានបង្រៀនពួកខ្មែរក្រហម សព្វគ្រប់ ហើយ ពួកគេក៏យកទៅសម្លាប់។

រីឯគ្រហស្ថបានស្លាប់ ក្នុងឆ្នាំនេះគឺលោកសិលា ឈុំ សំចៃ។ លោកបានសរសេរសៀវភៅមួយ អំពីដំណើរស្លាប់របស់កូនរបស់លោក ៨នាក់ ដែលត្រូវខ្មែរក្រហមយកទៅសម្លាប់។

លោកបានបង្ហាញជំនឿ យ៉ាងរឹងមាំលើព្រះជាម្ចាស់ ហើយលោកបានយកទៅសម្លាប់ដូចគ្នាដែរ នៅខេត្តបាត់ដំបង។

លោកគ្រូសិលា រស់ អេន។ លោកជាគ្រូអប់រំជំនឿ នៅភូមិកំពង់គោ។

លោកជួយជនភៀសខ្លួន នៅជ្រោយចង្វា។ លោកបង្ហាញខ្លួនថា ជាគ្រីស្តបរិស័ទ និងគ្រូបង្រៀន។

ឆ្នាំចុងក្រោយ នៃវីរកម្មរបស់អ្នក បម្រើរបស់ព្រះជាម្ចាស់ គឺឆ្នាំ១៩៧៨ លោកគ្រូយ៉ូសែប ចុង ជាគ្រូអប់រំជំនឿជនជាតិវៀតណាមម្នាក់ នៅភូមិកំពង់គោ។ លោកហ៊ាន ចេញមុខការពារលោកឪពុក វីណែ ពេលពួកទាហានវៀតកុង ចាប់លោកឪពុកទៅ។ លោកជួយជនភៀសខ្លួន ពេលនៅភ្នំពេញ។ មុនគេសម្លាប់ លោកចង់ថ្វាយកូនម្នាក់ របស់លោកទៅកាន់ព្រះជាម្ចាស់។

ភាពក្លាហានរបស់អស់អ្នកបម្រើរបស់ព្រះជាម្ចាស់ទាំងនេះ ជួយឲ្យយើងមានជំនឿកាន់តែរឹងមាំ ដោយសារក្នុងពេលដ៏សែនវេទនា ពួកគាត់បំពេញសកម្មភាពតាមមុខងារ និងតួនាទីរៀងៗខ្លួនដោយបង្ហាញ ធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ (តនៅទំព័រទី១៣)

(តពីទំព័រទី១២)
ចំពោះបងប្អូន ដែលត្រូវរង ទុក្ខវេទនា ដូចព្រះបន្ទូលថា "ព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ ទ្រង់គ្រប់លក្ខណ៍យ៉ាង ណាសុំឲ្យអ្នករាល់គ្នា បានគ្រប់លក្ខណ៍យ៉ាងនោះដែរ" (មថ ៥,៤៨)។

ជីវិតរបស់ពួកគាត់ បានរលាយសាបសូន្យនៅទឹកដីប្រទេសកម្ពុជា រួមជាមួយបងប្អូនខ្មែររាប់លាននាក់ ដោយសារការប្រឆាំងសាសនា ដែលជាលទ្ធិមួយ ដែលផ្ទុយនឹង គោលការណ៍របស់របបខ្មែរក្រហម។

អស់អ្នកបម្រើរបស់ព្រះជាម្ចាស់ ហាក់ដូចជាតំណាងរបស់គ្រាប់ពូជស្រូវ ដែលព្រះជាម្ចាស់ បានសាបព្រោះក្នុងប្រទេសនេះ ក្រោយមកនឹងកើតផល ផ្លែជាច្រើន ដូចព្រះបន្ទូលថា "គ្រាប់ស្រូវ ធ្លាក់ដល់ដីហើយបើមិនងាប់ទេ គ្រាប់ នោះនៅតែមួយដដែល។ ផ្ទុយទៅវិញ បើគ្រាប់ស្រូវនោះងាប់ វានឹងបង្កើតផលបានច្រើន។" (យហ១២,២៤) សូមព្រះអម្ចាស់យេស៊ូគ្រីស្ត ជួយឲ្យដំណើរការនៃការស៊ើបអង្កេតមូលហេតុ នៃមរណសាក្សី របស់ព្រះសហគមន៍កាតូលិកកម្ពុជា បានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គផង ដើម្បីប្រយោជន៍ខាងផ្លូវវិញ្ញាណ សម្រាប់គ្រីស្តបរិស័ទទាំងមូលផង៕

*អត្ថបទពីលោកបូជាចារ្យ រឿង ឆ័ត្រសិរី អ្នករៀបចំសំណុំឯកសារទ្រាប់មរណសាក្សីនៅកម្ពុជា*

# សម្តេចប៉ាប បង្កើតគណៈកម្មការពិសេស សម្រាប់កិច្ចការសុខភាព

វិទ្យុវ៉ាទីកង់ បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបង្កើតនូវគណៈកម្មការពិសេសមួយ កាលពីពេលថ្មីៗនេះ ដើម្បីទទួលខុសត្រូវកិច្ចការទំនាក់ទំនងការថែទាំសុខភាព ។

ក្រឹត្យស្តីអំពីការបង្កើត គណៈកម្មការនេះ ត្រូវបានចុះជាផ្លូវការ ដោយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ហើយក្រឹត្យនោះបានបញ្ជាក់ថា នេះគឺជាគណៈកម្មការដែលជាកម្មសិទ្ធិរបស់ព្រះសហគមន៍កាតូលិក ដើម្បីគ្រប់គ្រងថវិកា និង កិច្ចការផ្សេងៗទាក់ទងនឹងសុខភាព។

ប្រភពដដែល បានបញ្ជាក់ថា គណៈកម្មការនោះ គឺមានឈ្មោះជាផ្លូវការថា គណៈកម្មាធិការ សម្រាប់សកម្មភាពគតិយុត្តិសាធារណជន នៃព្រះសហគមន៍កាតូលិកក្នុងវិស័យថែទាំសុខភាព។

គណៈកម្មការនេះ នឹងមានសមាជិកភាពជាប្រធានមួយនាក់ និង អ្នកជំនាញការដែលទាក់ទងនឹងការថែទាំសុខភាព អចលនទ្រព្យ គ្រប់គ្រងអាជីវកម្មរដ្ឋបាល និងហិរញ្ញវត្ថុ ចំនួន ៦ នាក់៕

# សម្តេចប៉ាប ប្រកាសអំពីកំណែទម្រង់ស្ថាប័នតុលាការ

តាមសេចក្តីរាយការណ៍របស់វិទ្យុវ៉ាទីកង់ បានឲ្យដឹងថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចុះហត្ថលេខារួចមកហើយនូវក្រឹត្យច្បាប់ថ្មីមួយ កាលពីថ្ងៃសុក្រសប្តាហ៍មុនកន្លងទៅថ្មីៗនេះ ។

ប្រភពដដែលបានឲ្យដឹងថា តាមក្រឹត្យច្បាប់ដែលសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចុះហត្ថលេខា គឺទាក់ទងនឹងកំណែទម្រង់ស្ថាប័ន រ៉ូម៉ាំង រ៉ូតា (Roman Rota) ដែលគេដឹងថា គឺជាសាលាឧទ្ធរណ៍នៅក្នុងបុរីវ៉ាទីកង់ ។

ប្រភពដដែលបានបន្តថា កំណែទម្រង់នៃស្ថាប័នរ៉ូម៉ាំង រ៉ូតានេះ គឺពាក់ព័ន្ធនឹង ច្បាប់ស្តីអំពីអាពាហ៍ពិពាហ៍ ។

ប្រភពដដែលបានបន្តថា កំណែទម្រង់ស្ថាប័ន រ៉ូម៉ាំង រ៉ូតានេះ គឺជាចំណុចដែលផ្តួចផ្តើមឡើង នៅក្នុងព្រះសហគមន៍កាតូលិក តាំងតែពីសម័យកាលដែលបុរី វ៉ាទីកង់ដឹកនាំដោយសម្តេចប៉ាប យ៉ូហាន ប៉ូលទីពីរមកម្ល៉េះ៕

# សម្តេចប៉ាប ផ្តល់បាប-កថា ពិសេសមួយទៅអាជ្ញាធរស៊ីវិល និងអ្នកការទូតនៅម៉ិកសិក

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា កាលពីថ្ងៃទី១៣ កុម្ភៈ កន្លងទៅនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានរីករាយផ្តល់បាឋកថាពិសេសមួយទៅកាន់មន្ត្រីអាជ្ញាធរស៊ីវិល និងអ្នកការទូតម៉ិកស៊ិក នៅក្នុងអំឡុងពេលបំពេញទស្សនៈកិច្ចនៅក្នុងប្រទេសនេះ។

នៅក្នុងឱកាសនោះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា ៖ ចំណុចដ៏សំខាន់សម្រាប់មន្ត្រីគឺ ត្រូវតែមានធន្ទៈមួយគឺជាបុត្រធីតាដ៏ល្អ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក៏បានថ្លែងនូវការកោតសរសើរអំពីទីតាំងភូមិសាស្ត្រនៃប្រទេស ម៉ិកស៊ិក ដោយអះអាងថា គឺជាទឹកដៅមួយដែលមានធនធានធម្មជាតិសម្បូណ៌បែប ប៉ុន្តែបានសង្កត់ធ្ងន់អំពីអត្តសញ្ញាណ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានបន្តថា នៅពេលនេះទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ប្រទេសមួយជាតិសាសន៍មួយគឺ ភាពសម្បូបែបនៃធនធានយុវជន នេះគឺជារឿងដែលសំខាន់ ដែលយើងត្រូវតែដឹង។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ក៏បានសន្និដ្ឋានបូកសរុប ថា នៅក្នុងនាមជាអ្នកដឹកនាំមិនថាអ្នកនយោបាយ អ្នកអភិរក្ស អ្នកដឹកនាំស្ថាប័នសង្គម គឺត្រូវតែយកចិត្តទុកដាក់នៅក្នុងការផ្តល់ ឱកាសដល់ប្រជាពលរដ្ឋ ។

# សន្តយ៉ូហាន បាទីស្ត



លោកយ៉ូហាន ដែលយើងតែងហៅថា "យ៉ូហានបាទីស្ត" ជាកូនរបស់លោកសាការីជាបូជាចារ្យ បម្រើព្រះជាម្ចាស់ នៅក្រុងយេរូសាឡឹម និងអ្នកស្រីអេលីសាបិតជាស្ត្រីអារ។

យ៉ូហានធំពេញវ័យ នៅសម័យដែលគ្មាននរណាម្នាក់ចង់ស្តាប់ និងប្រព្រឹត្តតាមព្រះបន្ទូល របស់ព្រះជាម្ចាស់ទេ។

យ៉ូហាន ខឹងនឹងគេខ្លាំងណាស់។ ថ្ងៃមួយគាត់ចាកចេញពីទីក្រុង ទៅរស់នៅក្នុងវាលរហោស្ថាន ដូចជាឥសីម្នាក់ ដើម្បីរិះគិត អំពីព្រះជាម្ចាស់ និង ត្រៀមខ្លួន បំពេញបេសកកម្មរបស់គាត់។ លោកស្លៀកសំលៀកបំពាក់ ធ្វើពីរោមអូដ្ឋ ហើយពាក់ខ្សែក្រវ៉ាត់ ធ្វើអំពីស្បែក។ គាត់បរិភោគកណ្តូប និងទឹកឃ្មុំ។

នៅវាលរហោស្ថាន លោកយ៉ូហាន ប្រកាស ឲ្យប្រជាជនកែប្រែចិត្តគំនិត ព្រោះព្រះរាជ្យ របស់ព្រះជាម្ចាស់ជិតមកដល់ហើយ។ មនុស្សជាច្រើនបាន មកទទួលពិធីជ្រមុជទឹក ពីលោកនៅទន្លេយ័រដាន់។ លោកក៏បាន ធ្វើពិធីជ្រមុជទឹក ឲ្យព្រះយេស៊ូតាមសំណូមរបស់ព្រះអង្គដែរ។ លោកយ៉ូហាន ជាមនុស្សសុចរិត លោកធ្លាប់បានស្តីបន្ទោសដល់ស្តេចហេរ៉ូដ នៅពេលព្រះអង្គយកមហេសី របស់អនុជមកធ្វើជាមហេសីរបស់ព្រះអង្គ។ ព្រះនាងហេរ៉ូឌីយ៉ាដា ខឹង និងចងគំនុំចង់សម្លាប់លោកជាខ្លាំង។ លោកឮគេនិយាយអំពីព្រះយេស៊ូ ដោយអាណិតស្រឡាញ់អ្នកបាប តែមិនដាក់ទោសគេទេ។ លោកឆ្ងល់អំពីរឿងនេះ ហើយបានចាត់សិស្សឲ្យទៅជួបព្រះយេស៊ូ។ ព្រះយេស៊ូតបទៅសិស្ស របស់លោកយ៉ូហាន ថា "ចូរប្រាប់លោកយ៉ូហាននូវហេតុការដែលអ្នកបានឃើញទៅ មនុស្សខ្វិនដើរបានមនុស្សខ្វាក់មើលឃើញ មនុស្សឃ្លង់ជាស្អាតបរិសុទ្ធ ....."។

តាំងពីពេលនោះមក លោកយ៉ូហាន ទទួលស្គាល់ថា ព្រះយេស៊ូជាព្រះសង្គ្រោះពិតមែន។

ថ្ងៃមួយគេនាំយក លោក យ៉ូហាន ទៅកាត់ក តាមបញ្ជារបស់ស្តេចហេរ៉ូដ ដែលធ្វើតាមសំណូមពរនៃពាក្យសន្យានឹងបុត្រីរបស់ព្រះនាង ហេរ៉ូឌីយ៉ាដា ក្នុងពិធីជប់លៀងមួយ។

កាលពីព្រះយេស៊ូដឹងរឿងនេះ ព្រះអង្គមានបន្ទូលថា "ខ្ញុំសុំប្រាប់អ្នករាល់គ្នាឲ្យដឹងច្បាស់ថា ក្នុងចំណោមមនុស្សដែលកើតមកក្នុងលោកនេះ គ្មាននរណាម្នាក់មានឋានៈធំជាង លោកយ៉ូហានបាទីស្តឡើយ"។

# លោកអភិបាលអូលីវីយេ៖ និស្សិតត្រូវបង្កើនសមត្ថភាពដើម្បីអនាគត

លោកអូលីវីយេ ជ្មិតអីស្លែរ ជានាយកវិទ្យាស្ថានសន្ត ប៉ូល និងអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានមានប្រសាសន៍ជំរុញ និងលើកទឹកចិត្តឲ្យនិស្សិតទាំងអស់ ខិតខំប្រឹងប្រែងសិក្សាបង្កើនគុណភាព និងសមត្ថភាពជំនាញផ្ទាល់ខ្លួន ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសនាពេលខាងមុខ ។

លោកអភិបាលបានថ្លែងដូចនេះ នៅក្នុងពិធីបើកបវេសនកាល ឆ្នាំសិក្សា ២០១៥-២០១៦ និងពិធីចែកសញ្ញាបត្របរិញ្ញាបត្រ ដល់និស្សិតជំនាន់ទី២ ផ្នែកព័ត៌មានវិទ្យា និងនិស្សិតជំនាន់ទី១ ផ្នែកអក្សរសាស្ត្រអង់គ្លេស និងគ្រប់គ្រងទេសចរណ៍ នៅវិទ្យាស្ថានសន្តប៉ូល ស្ថិតក្នុងភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១៥ ធ្នូ ២០១៥។

ពិធីនោះបានប្រព្រឹត្តទៅ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ពីសំណាក់ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយនិងអាជ្ញាធរមូលដ្ឋាន លោកអភិបាលស្រុកត្រាំកក់ លោកប្រធានការិយាល័យអប់រំស្រុក លោកគ្រូអ្នកគ្រូ និស្សិត រួមជាមួយមាតាបិតា អាណាព្យាបាល សិស្សនិស្សិតយ៉ាងច្រើនកុះករ។

លោកអភិបាល បានមានប្រសាសន៍ថា សម្រាប់វិទ្យាស្ថានសន្តប៉ូល មានគោលដៅ ផ្តល់ឲ្យយុវជនយុវនារី ទទួលបាននូវការអប់រំពីកុមារ រហូតដល់ពួកគេក្លាយទៅជាមនុស្សពេញវ័យ ដើម្បីបំពេញតួនាទីរបស់គេ នៅក្នុងសង្គមបច្ចុប្បន្ននេះ។ ទស្សនវិស័យរបស់វិទ្យាស្ថានសន្តប៉ូល បានខិតខំអនុវត្តនូវគរុកោសល្យនៃការបង្រៀនប្រកបដោយគុណភាព ដើម្បីជួយឲ្យនិស្សិត ទទួលបាននូវការសិក្សាទាំងស្រុង ពោលគឺទទួលបានទាំងចំណេះដឹង ទាំងសីលធម៌ និងសមត្ថភាពជំនាញពិតប្រាកដ ។



*វិធីប្រគល់សញ្ញាបត្រ ជូននិស្សិតនៅវិទ្យាស្ថានសន្តប៉ូល ក្រោមអធិបតីរបស់ ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន។ រូបថត៖ សុធារិទ្ធ*

លោកបន្តទៀតថា ពិធីបើកឆ្នាំសិក្សា និងចែកសញ្ញាបត្រនៅថ្ងៃនេះ គឺជាលទ្ធផលដែលបានបង្ហាញឲ្យឃើញ នូវការខិតខំប្រឹងប្រែងរួមគ្នា ពីសំណាក់លោកសាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ សិស្សនិស្សិត និងគណៈគ្រប់គ្រងនៃវិទ្យាស្ថានប៉ូលទាំងមូល ក្នុងការជួយដល់សង្គមកម្ពុជា តាមរយៈការ ផ្តល់ការអប់រំមួយប្រកបទៅដោយគុណភាព សម្រាប់និស្សិតទាំងអស់ក្នុងការចូលរួមកិច្ចអភិវឌ្ឍន៍ប្រទេសនាពេលអនាគត ។

លោកអភិបាល ក៏បានថ្លែងអំណរគុណចំពោះ វត្តមានឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអរគុណចំពោះ លោកគ្រូអ្នកគ្រូ លោកសាស្ត្រាចារ្យ គណៈគ្រប់គ្រងវិទ្យាស្ថានសន្តប៉ូលទាំងអស់ ក្នុងការជួយឲ្យវិទ្យាស្ថានសន្តប៉ូល បានទទួលនូវការរីកចម្រើន ។

ឯកឧត្តមបណ្ឌិតហង់ ជួនណារ៉ុន បានមានប្រសាសន៍កោតសសើរចំពោះ លោកអភិបាលអូលីវីយេ និងគណៈគ្រប់គ្រងវិទ្យាស្ថានសន្តប៉ូលទាំងអស់ និងព្រះសហគមន៍កាតូលិក ដែលបានខិតខំប្រឹងប្រែងរួមគ្នា ដោយយកអស់ពីកម្លាំងកាយចិត្ត គាំទ្រលើការបណ្តុះបណ្តាលធនធានមនុស្ស នៅប្រទេសកម្ពុជា តាមរយៈវិស័យអប់រំ ។

ឯកឧត្តមបណ្ឌិត បានលើកទឹកចិត្តចំពោះនិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រទាំងអស់ ត្រូវខិតខំប្រឹងប្រែងជាបន្តទៀតនូវការសសេរ និងការពារសារណាបញ្ចប់ការសិក្សារបស់ខ្លួនឲ្យបានគ្រប់ៗគ្នា។ ឯកឧត្តមបណ្ឌិតបានបញ្ជាក់ថា៖ "ការសសេរសារណាគឺពិតជាមានសារសំខាន់ណាស់ សម្រាប់ជីវិតជានិស្សិត ដែលបានបញ្ចប់បរិញ្ញាបត្រហើយក៏ជាគុណប្រយោជន៍សម្រាប់និស្សិតខ្លួនឯងផ្ទាល់ នៅក្នុងការបញ្ជាក់អំពី សមត្ថភាពរបស់ខ្លួន នៅក្នុងការស្វែងរកការងារធ្វើនាពេលអនាគត។

យុវនិស្សិតអ៊ុន តាក់ ជានិស្សិតជំនាន់ទី២ផ្នែកព័ត៌មានវិទ្យាដែលនឹងត្រូវទទួលសញ្ញាបត្របរិញ្ញាបត្រ នាពេលនោះ បានឲ្យដឹងថា ប្អូនមានចិត្តរំភើបរីករាយ ក្នុងអំណរសប្បាយ ដែលបានទទួលសញ្ញាបត្រនាថ្ងៃនេះ។ក្រោយពីបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានសន្តប៉ូល សព្វថ្ងៃរូបប្អូនមានការងារជាមួយនឹងប្រាក់បៀវត្សសមរម្យ៕ *ដោយឡុង សម្ជស្ស*

# ព្រះសហគមន៍តំបន់មេមត់ដាក់ទិសដៅសំខាន់២សម្រាប់យុវជន

ព្រះសហគមន៍តំបន់ មេមត់ និងកោះរការ បានរៀបចំផែនការសម្រាប់យុវជនក្នុងឆ្នាំ ២០១៥-២០១៦នេះ ដើម្បីលើកកម្ពស់តម្លៃនៃការសិក្សារបស់យុវជន និងឲ្យយុវជនយល់ដឹងបន្ថែមអំពីភាពអវិជ្ជមាននៃអំពើហិង្សា។

ផែនការនេះ បានធ្វើឡើងក្រោយពីជំនួបរវាងគណៈកម្មការ នៃព្រះសហគមន៍នានា ក្នុងតំបន់បានមកជួបជុំគ្នាកាលពីថ្ងៃទី០៩ ធ្នូកន្លងទៅ។

តាមប្រសាសន៍របស់លោកបូជាចារ្យ ផាន បូរី ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កាតូលិកកោះរការ និងជាជំនួយការរបស់លោកបូចារ្យ សេរ៉ាល់ វ៉ូសាំង បានឲ្យដឹងថា៖ គម្រោងក្នុងឆ្នាំនេះសម្រាប់យុវជន គឺឲ្យពួកគេទទួលបានការអប់រំអំពីហិង្សា និងឲ្យពួកគាត់ផ្តោតអារម្មណ៍លើការសិក្សាជាសំខាន់។

លោកបូជាចារ្យបន្តថា "ដោយសារយុវជននាពេលបច្ចុប្បន្នតែងតែមានចិត្តឆែវឆាវ សេពនូវគ្រឿងស្រវឹង ពេលខ្លះអាចបង្ករឲ្យមាន អំពើហិង្សាជាមួយគ្នា ហើយអាចបណ្តាលឲ្យមានផលប៉ះពាល់ដល់ក្រុមគ្រួសារ និងការសិក្សារបស់ពួកគេ"។

លោកបូជាចារ្យបូរី បញ្ជាក់ទៀតថា គម្រោងនេះ គឺចង់ឲ្យយុវជនទាំងនោះចេះសម្លឹងមើលអនាគតរបស់ខ្លួនថា គេចង់រៀនអ្វី? គេធ្វើយ៉ាងណាដើម្បីឲ្យទទួលបាននូវភាពជោគជ័យនៅក្នុងការសិក្សា។ ពេលគេមានបញ្ហានៅក្នុងការសិស្សា តើត្រូវដោះស្រាយយ៉ាងណា? ហើយអ្វីដែលពិសេសជាងនេះទៅទៀត គឺឲ្យពួកគេចេះគិតអំពីអនាគតរបស់ពួកគេជាសំខាន់។ លោកបូជាចារ្យរូបនេះ បាន បន្ថែមថា៖ លោក និងមានគម្រោងដើម្បីជួបប្រឹក្សាផ្ទាល់ជាមួយនឹងយុវជនម្នាក់ៗ ដើម្បីលើកទឹកចិត្ត និងផ្តល់យោបល់ដល់ពួកគេផង៕

*ដោយ៖ រឿន ស្រីម៉ាច*

# ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ជាខួបសម្តេចតេជោធ្វើនាយករដ្ឋមន្ត្រីគម្រប់៣១ ឆ្នាំ

នៅក្នុងឋានៈជានាយករដ្ឋមន្ត្រីនៅក្នុងតំណែងនាពេលបច្ចុប្បន្ននេះ សម្តេចតេជោ ហ៊ុន សែន កាលពីថ្ងៃទី១៤ មករា បានប្រកាសថា ថ្ងៃនោះ គឺជាថ្ងៃខួបទី៣១ ឆ្នាំដែល សម្តេចត្រូវបាន ជ្រើសតាំងជានាយករដ្ឋមន្ត្រី។

សម្តេចតេជោ ហ៊ុន សែន បានសរសេរនៅក្នុងហ្វេសបុកជាផ្លូវការថា "៣១ ឆ្នាំមុន គឺនៅថ្ងៃ១៤ មករា ១៩៨៥ នោះ ហើយដែលរដ្ឋសភាបានបោះឆ្នោតជ្រើសរើសខ្ញុំព្រះករុណាខ្ញុំជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី (នាយករដ្ឋមន្ត្រី)នៃរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតកម្ពុជា "។

សម្តេចតេជោ បានបន្តទៀតថា បន្ទាប់ពីការបំពេញភារកិច្ចជារដ្ឋមន្ត្រីការបរទេស និង ជាឧបនាយករដ្ឋមន្ត្រី រយៈពេល៦ឆ្នាំ ហើយក៏បានបំពេញមុខនាទីជានាយករដ្ឋមន្ត្រីស្តីទីប្រមាណជាជាង ៣ខែ តាំងពីពេលដែល ឯកឧត្តម ចាន់ ស៊ី ចេញទៅព្យាបាលជម្ងឺនិងទទួលមរណភាពនៅទីក្រុងមូស្គូ។

សម្តេចតេជោ ហ៊ុន សែន បានអះអាងថា "នៅក្នុងការបោះឆ្នោតជាសម្ងាត់នៅក្នុងរដ្ឋសភានៅពេលនោះ គឺសម្តេចទទួលបាននូវសម្លេងឆ្នោតគាំទ្រ ១០០%។ ខណៈដែលនាយករដ្ឋមន្ត្រី ២រូប មុនខ្ញុំតែង មានសន្លឹកឆ្នោតប្រឆាំងមិនតិចជាង ៥សម្លេង"។

ដោយឡែកកាលពីថ្ងៃទី២០ ខែដដែល សម្តេចតេជោ នាយករដ្ឋមន្ត្រីក៏បានរំលឹកនូវ ប្រវត្តិសំខាន់ៗមួយចំនួននៃការចាប់បដិសន្ធិសន្តិភាពនៅកម្ពុជា។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "ថ្ងៃទី២០ ខែមករា ឆ្នាំ១៩៨៨- ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ គឺជាខួប ២៨ ឆ្នាំនៃការចរចារសន្តិភាពដំណាក់កាលទី២ រវាងអតីតព្រះមហាក្សត្រកម្ពុជា សម្តេចព្រះ នរោត្តម សីហនុ និង ខ្ញុំព្រះករុណា នៅ Saint -Germainen-Laye។ ការចរចារលើកទី១ គឺនៅថ្ងៃទី២ ខែធ្នូ ១៩៨៧ នៅ Fere-En-tardenois, ប្រទេសបារាំង ដែលបានចេញជាសេចក្តីប្រកាសរួមក្នុងការស្វែងរកសន្តិភាពពិតប្រាកដ សម្រាប់កម្ពុជា។ កិច្ចចរចារពេញមួយថ្ងៃ នៅថ្ងៃទី ២០ មករា ១៩៨៨ គឺបានពិភាក្សាលើទិដ្ឋភាពរួមដើម្បីរកដំណោះស្រាយផ្ទៃក្នុង រវាងខ្មែរ និងខ្មែរដើម្បីបញ្ចប់សង្គ្រាមទាំងស្រុង ដែលមានខ្ញុំព្រះករុណា និងអតីតសម្តេចព្រះនរោត្តម សីហនុ"។

# សម្បទានរបស់រាជរដ្ឋាភិបាលជូនពលរដ្ឋនៅចុងឆ្នាំ២០១៥ និងដើមឆ្នាំ២០១៦

នៅដើមឆ្នាំ២០១៦ នេះរាជរដ្ឋាភិបាលកម្ពុជាបានធ្វើសម្បទានជាបន្តបន្ទាប់ជូនប្រជាពលរដ្ឋ សំដៅកាត់បន្ថយភាពថ្នាំងថ្នាក់ និងជំរុញក៏ដូចជាលើកស្ទួយសេដ្ឋកិច្ចពលរដ្ឋ។

សម្បទានដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើដំបូងគេ គឺការប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា តាមបណ្តាញសង្គមហ្វេសបុក ផ្លូវការរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន លុបចោលសម្បទានគ្រប់គ្រង និងថៃទាំកំណាត់ផ្លូវវែងស្រែង ។

បន្ទាប់មកទៀតគឺ ការប្រកាសផ្អាកការរឹតបន្តឹង ច្បាប់ចរាចរណ៍ផ្លូវគោកថ្មីលើចំណុចជាច្រើន ដើម្បីពិនិត្យភាពខ្លាំង និងភាពខ្សោយនៃច្បាប់ក្រោយពេលដែលការអនុវត្តច្បាប់នេះ បានបង្កការរិះគន់យ៉ាងច្រើនពីប្រជាពលរដ្ឋ ។

សម្បទានដែលគួរឲ្យកត់សំគាល់មួយទៀតគឺ ការប្រកាសលុបចោលតម្រូវការឲ្យម្ចាស់បើកបរម៉ូតូចាប់ពី ១២៥CC ចុះក្រោមធ្វើប័ណ្ណបើកបរ និងការប្រកាសបង្កឲ្យមានភាពងាយស្រួលផ្សេងៗ សម្រាប់ពលរដ្ឋកម្ពុជា នៅក្នុងការធ្វើប័ណ្ណបើកបរយានយន្តផ្សេងៗទៀត ។

ក្រៅពីនោះ ប្រមុខរាជរដ្ឋាភិបាលក៏បានប្រកាសតាមបណ្តាញសង្គមផ្លូវការរបស់សម្តេច លុបចោល នៅការយកពន្ធប្រថាប់ត្រា នៅលើការផ្ទេរកម្មសិទ្ធិ ពីឪពុកម្តាយទៅកូន ពីប្តីទៅប្រព័ន្ធ ពីប្រពន្ធទៅប្តី និងបងទៅប្អូន ។ល។

ចុងក្រោយសម្បទាន ដែលរាជរដ្ឋាភិបាលបានធ្វើ ហើយក៏បង្កនូវការគាំទ្រពីសំណាក់ប្រជាពលរដ្ឋកម្ពុជា ជាច្រើននោះ គឺការលុបចោលអាជ្ញាប័ណ្ណ និងដកសិទ្ធិគ្រប់គ្រងសម្បទានគ្រប់គ្រង និងថៃទាំផ្លូវជាតិលេខ៤ ពីក្រុមហ៊ុនអេហ្សិត ដោយទុកឲ្យផ្លូវនេះ អាចប្រជាពលរដ្ឋធ្វើដំណើរដោយសេរី ដោយគ្មានបង់ប្រាក់។

# ម្រះជាប្រភេទបន្លែ ដែលគេអះអាងថា អាចជួយទប់ស្កាត់ជំងឺមហារីក និងទឹកនោមផ្អែម

តាមការស្រាវជ្រាវជាច្រើន បានឲ្យដឹងថា ម្រះអាចជួយទប់ស្កាត់ជំងឺមហារីក និងទឹកនោមផ្អែម ដោយសារវាមានផ្ទុកសារជាតិ ជីវជាតិយ៉ាងច្រើនដែលមានប្រយោជន៍ចំពោះ សុខភាព មនុស្ស។

ពពួកវីតាមីន ដែលមានប្រយោជន៍នៅក្នុងបន្លែម្រះ គឺរួមមានវីតាមីន B9, A, C ប៉ូតាស្យូម និងសារជាតិប្រឆាំងអុកស៊ីតកម្ម បេតា ការ៉ូតែន (beta-Carotene) និង លូតែន (Lutein)។

សារជាតុជីវជាតិទាំងនេះ គឺបណ្តាលឲ្យម្រះក្លាយជាប្រភេទបន្លែ ដែលមានប្រសិទ្ធភាព ដ៏ប្រសើរចំពោះដំណើរការបំប្លែងហ្លួសាមីន ធ្វើឲ្យថយចុះការដឹកជញ្ជូនសារជាតិជីវជាតិ ចិញ្ចឹមកោសិកាមហារីកទៅក្រពេញលំពែង ។

ចំពោះអ្នកជំងឺទឹកនោមផ្អែម ម្រះមានលទ្ធភាព សម្រួលកម្រិតអាំងស៊ុយ លីន និងគ្លុយកូសក្នុងសរីរាង្គ។ ម្រះជួយបញ្ចុះជាតិស្ករក្នុងឈាម និងបន្ថយយ៉ាងច្រើននូវសារជាតុអគ្រាស្ករក្នុង ឈាមសម្រាប់អ្នកជំងឺទឹកនោមផ្អែម៕

# ពាណិជ្ជកម្ម នាំចេញកម្ពុជា មានទំហំ៤,៥ ពាន់លាន ដុល្លារ

លោក ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា ការនាំចេញរបស់កម្ពុជានាឆ្នាំ២០១៥នេះ គឺមានតម្លៃសរុបប្រមាណជា ៤,៥ ពាន់លានដុល្លារ ។

លោកបានមានប្រសាសន៍ នៅក្នុងឱកាស បិទសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ ២០១៥ និងលើកទិសដៅការងារ ពាណិជ្ជកម្មឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម កាលពីរសៀលថ្ងៃទី៩ ធ្នូ ថាការនាំចេញរបស់កម្ពុជា នៅក្នុងឆ្នាំ២០១៥នេះ គឺមានកំណើនកើនឡើង ប្រមាណជា ២៥ភាគរយ ធៀបនឹងឆ្នាំ២០១៤ ដែលមានទឹកប្រាក់តែ ៣.៦០០ លាន ដុល្លារ ។

លោកបានបន្តថា ផលិតផលដែលកម្ពុជានាំចេញរួមមាន សម្លៀកបំពាក់ ស្បែកជើង អង្ករ កសិផលមាន ដូចជាដំណាប់ស្វាយ ស្វាយក្ចាស់សេ ដំឡូងផ្វា ម្ទេសស្រស់ ស្លឹកទាបបារាំង ទៅប្រទេសកូរ៉េ និងប្រទេសថៃឡង់ដ៏ទោចក្រយាន និងផលិតផលផ្សេងៗទៀតក្នុងឆ្នាំ។

លោកបានបន្តថា ក្រៅពីការនាំចេញសម្រាប់២០១៥នេះ ក្រសួងរកចំណូលបង់ចូលថវិការជាតិមានទឹកប្រាក់សរុនមានចំនួន ២០២.០៥២,៩០លានរៀល ប្រៀបធៀប នឹងឆ្នាំ២០១៤ គឺកើនឡើងប្រមាណជា ៨,៥ភាគរយ។ ហើយក្រសួងបានចុះបញ្ជីថ្មី ក្រុមហ៊ុនការិយាល័យតំណាងពាណិជ្ជកម្ម និង សាខាក្រុមហ៊ុនបរទេស បានចំនួន ៣.៧៩៨ក្រុមហ៊ុនធៀបនឹងឆ្នាំ២០១៤ គឺមានកំណើន១១,៩៤ភាគរយ៕

# តំណាងកម្ពុជាមួយរូបទទួលពានរង្វាន់ជាសកម្មជនឆ្នើមគាំពារជនភៀសខ្លួន

ស្ត្រីមួយរូប ដែលកំពុងតែធ្វើការនៅក្នុងប្រទេសកម្ពុជា នៅក្រោមឆ័ត្រ នៃភ្នាក់ងារជួយជនភៀសខ្លួន ដេស្វីត (JRS) របស់ក្រុមគ្រួសារសហជីវិនព្រះយេស៊ូ ត្រូវបានជាប់និងទទួលពានរង្វាន់ជាសកម្មជនឆ្នើមគាំពារជនភៀសខ្លួន នៃភ្នាក់ងារជួយជនភៀសខ្លួន ដេស្វីតពិភពលោក ។

ស្ត្រីឆ្នើមរូបនេះ ត្រូវបានគេដឹងថា គឺជាបងស្រី ដេនីស កូហ្គលេន ដែលជាស្ត្រីជនជាតិអូស្ត្រាលី ប៉ុន្តែបានស្ម័គ្រចិត្តចូលបម្រើការងារមនុស្សធម៌ នៅកម្ពុជាតាំងពីទស្សវត្សរ៍នៃឆ្នាំ១៩៨០។ ដោយនៅក្នុងអំឡុងពេលនោះបងស្រី បានចូលមកជួយជនភៀសខ្លួនកម្ពុជា នៅតាមជំរុំជនភៀសខ្លួន នៅតាមតំបន់ព្រំដែនកម្ពុជា ហើយក្រោយមកបងស្រីក៏បានធ្វើដំណើរចូលមកបំពេញកិច្ចការមនុស្សធម៌ផ្សេងៗ នៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៩២ មក ដល់ពេលបច្ចុប្បន្ននេះ ។

ពានរង្វាន់ដ៏កិត្តិយសសម្រាប់ស្ត្រីឆ្នើមដែលបានមកជួយសង្គមកម្ពុជា អស់រយៈពេលប្រមាណជា ៣៥ឆ្នាំ រូបមួយនេះត្រូវបានប្រកាសក្នុងឱកាសនៃការអបអរគម្រប់ខួបលើកទី ៣៥ឆ្នាំ នៃថ្ងៃបង្កើតភ្នាក់ងារជួយជនភៀសខ្លួនដេស្វីត (JRS) របស់ក្រុមគ្រួសារសហជីវិនព្រះយេស៊ូនៅកម្ពុជា កាលពីពេលថ្មីៗកន្លងទៅនេះ។

ពានរង្វាន់នេះ មិនមែនជាកិត្តិយសសម្រាប់តែបងស្រីប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់សង្គម និងប្រជាជាតិកម្ពុជាផងដែរ ដោយសារបងស្រី គឺជាបុគ្គលម្នាក់ក្នុងចំណោមសកម្មជនឆ្នើមបីរូប ដោយនៅក្នុងនោះគឺ មានម្នាក់មកពីអឺរ៉ុបម្នាក់នៅសហរដ្ឋអាមេរិក ដែលទទួលបានពានរង្វាន់នេះ ។

លោក អេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគបាត់ដំបង បានបង្ហាញ ពីការចាប់អារម្មណ៍ និងកោតសសើរជាខ្លាំងចំពោះកិច្ចការ និងស្នាដៃជាច្រើនរបស់បងស្រីដេនីស ចាប់តាំងពីពេលបងស្រីបានជួយដល់ជនភៀសខ្លួនខ្មែរ នៅជំរំជនភៀសខ្លួនកម្ពុជា-ថៃ រហូតមកដល់ចូលក្នុងប្រទេសកម្ពុជា ដោយធ្វើដំណើររួមជាមួយពួកគ បំរើពួកគេ និងផ្តល់ក្តីសង្ឃឹមសម្រាប់ពួកគេរហូតមក ។

លោកអភិបាល បានមានប្រសាសន៍ថា "បងស្រីគឺជាជនគំរូមួយ សម្រាប់កិច្ចការមនុស្សធម៌។ ពានរង្វាន់ដែលបងស្រីបានទទួល មិនមែនជាកិត្តិយសសម្រាប់តែបងស្រីប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាចំណែកមួយផ្នែក និងជាមោទនភាពរបស់បងប្អូនខ្មែរផងដែរ" ។




*បងស្រីដេនីសសកម្មជនជនភៀសខ្លួននៃអង្គការដេស្វីត*

បងស្រី បានបញ្ជាក់ថា "ខ្ញុំរំភើប និងសប្បាយចិត្តប៉ុន្តែទន្ទឹមនឹងការសប្បាយចិត្តខ្ញុំក៏ព្រួយចិត្ត និងបារម្ភផងដែរចំពោះបញ្ហាជនភៀសខ្លួន ជាពិសេសគឺជនភៀសខ្លួនម៉ុងតាញ៉ា ដោយសារតែពេលនេះ រដ្ឋាភិបាលកម្ពុជាអត់ទទួលស្គាល់ពួកគេ ហើយអត់ព្រមកត់ឈ្មោះពួកគេ "។

បងស្រី ដេនីស គឺជាសមាជិកនៃក្រុមបព្វជិតា នៃសេចក្តីមេត្តាករុណា ហើយ សព្វថ្ងៃ បងស្រីជាកំពុងតែបម្រើ-ការនៅក្នុងឋានៈ ប្រធានភ្នាក់ងារជួយជនភៀសខ្លួនដេស្វីត (JRS) ប្រចាំប្រទេសកម្ពុជា។

បងស្រី ដេនីស បានទទួលមេដាយ និងរង្វាន់ជាសកម្មជនឆ្នើម ដែលជួយគាំពារជនភៀសខ្លួន នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ កន្លងទៅថ្មីៗនេះ ។

គួររំលឹកថា ភ្នាក់ងារជួយជនភៀសខ្លួនដេស្វីត ត្រូវបានបង្កើតឡើងដោយលោកបូជាចារ្យអារ៉ូពេ នៃក្រុមសហជីវិនព្រះយេស៊ូ។ លោកធ្លាប់បានរស់នៅ និងឆ្លងកាត់ការទម្លាក់ គ្រាប់បែកប៉ារ៉ូមាណូនៅក្រុងហេរ៉ូស៊ីម៉ា ហើយលោកបានដឹងអំពីវិសាលភាព នៃសោកនាដ-កម្មនៃក្រុមជនភៀសខ្លួននោះ។ លោកបានមើលឃើញថា ជាបញ្ហាប្រឈមដែលសមាគមដេស្វីត មិនអាចព្រងើយកន្តើយបាន ប្រសិនបើពួកគេនៅតែភក្តីភាពចំពោះការត្រាស់ហៅរបស់ពួកគេ។ លោកចង់ឲ្យភ្នាក់ងារជួយជនភៀសខ្លួនដេស្វីត បំពេញសេចក្តីត្រូវការរបស់មនុស្ស និងខាងផ្លូវវិញ្ញាណសម្រាប់ជនភៀសខ្លួនទាំងនោះ មិនត្រឹមតែតម្រូវការអាហារ និងជម្រកចំពោះមុខប៉ុណ្ណោះទេ ថែមទាំងតម្រូវការរបស់ពួកគេចង់ឃើញការគោរពសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ ស្តាប់ពួកគេនិយាយព្រមទាំងការលួងលោម និងលើកទឹកចិត្តពួកគេផងដែរ។

តាមរបាយការណ៍ របស់ឧត្តមស្នង-ការសហប្រជាជាតិ សម្រាប់ជនភៀសខ្លួន បានប៉ាន់ប្រមាណថា នៅពេលថ្មីៗនេះ នៅទូទាំងពិភពលោក មានជនភៀសខ្លួនជិត ៦០លាននាក់ ដែលនេះ គឺជាចំនួនខ្ពស់បំផុតពុំធ្លាប់មានចាប់តាំងពីសង្គ្រាមលោកលើកទី២មក ។ ស្ថិតិទាំងនេះ បានកប់នៅក្នុងមនុស្សដែលពួកគេម្នាក់ៗមានឈ្មោះ មានមុខមានរឿងរ៉ាវ សេចក្តីថ្លៃថ្នូមិនអាចយកទៅបាន ដែលជារបស់ពួកគេ ក្នុងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់។

ឆ្លើយតបនឹងតម្រូវការនេះ ភ្នាក់ងារជួយជនភៀសខ្លួន ដេស្វីត គឺជាភ្នាក់ងារដ៏សកម្មមួយ។ ក្នុងពេលបច្ចុប្បន្នភ្នាក់-ងារជួយជនភៀសខ្លួនដេស្វីត បានធ្វើសកម្មភាពនៅក្នុងតំបន់ខុសគ្នា ចំនួន១០ ដោយមានគម្រោងនៅក្នុងប្រទេសចំនួន ៤៥ ដែលតាមរយៈប្រទេស ទាំងនោះ ភ្នាក់ងារនេះ បានផ្តល់សេវា ឧបត្ថម្ភដល់ជនភៀសខ្លួន និងជួយមនុស្សដែលបានធ្វើការចំណាកស្រុក ក្នុងប្រទេស។ ក្រុមដេស្វីត បព្វជីតា បានកំពុង ធ្វើការរួមជាមួយសហការី ជាគ្រហស្ថយ៉ាងច្រើននាក់ និងជួយជនភៀសខ្លួនចំនួនយ៉ាងច្រើនសន្ធឹក។ នៅក្នុងពេលទាំងអស់នេះ បងប្អូននៅតែ ភក្តីភាពចំពោះ ឧត្តមគតិរបស់លោក បូជាចារ្យ អារូពេ និងចំពោះគោលដៅជាមូលដ្ឋានបីនៃបេសកកម្មរបស់ខ្លួនគឺ ៖ រួមដំណើរជាមួយគ្នា បម្រើជាមួយគ្នា និងការពារសិទ្ធិជនភៀសខ្លួន។

ភ្នាក់ងារជួយជនភៀសខ្លួន ដេស្វីត បានធ្វើការ ដើម្បីផ្តល់សេចក្តីសង្ឃឹម និងអនាគតដល់ជនភៀសខ្លួន ភាគច្រើនតាមរយៈ ការផ្តល់សេវាអប់រំរបស់ខ្លួន ហើយមានសារៈសំខាន់ពិសេស ឲ្យបានទៅដល់មនុស្សជាច្រើន។ ផ្តល់ការអប់រំជាទស្សនៈ នៃការចែករំលែកកាន់តែច្រើនថែមទៀត។ ការអប់រំជាអ្វីមួយដោយផ្តល់ជូន ជាធនធាន ដល់ជនភៀសខ្លួន ដើម្បីឲ្យពួកគេឈានទៅមុខហួសពីការរស់រានមានជីវិត ដើម្បីរក្សាភ្លើង នៃសេចក្តីសង្ឃឹមឲ្យមានភាពរស់រវើក ដើម្បីភាពជឿជាក់ក្នុងពេលអនាគត និងដើម្បីបង្កើតផែនការ។ គម្រោងទាំងអស់ មានគោល បំណងគឺ ៖ ជួយ ជនភៀសខ្លួន ឲ្យរីកចម្រើនក្នុងការ ទុកចិត្តលើខ្លួនឯង ដើម្បីសម្រេចបានសក្តានុពលខ្ពស់បំផុត ជាប់ជាមួយពួក គេ និងដើម្បីអាចការពារសិទ្ធិរបស់ពួក គេ ជាបុគ្គល និងសហគមន៍៕

*ដោយឡុង សម្ផស្ស*

**ថ្ងៃអាទិត្យទី៤រដូវអប់រំពិសេស**
**( លក ១៥,១-៣.១១ខ-៣២ )**

ប្រស្នាក្នុងអត្ថបទនេះ នាំឲ្យយើងយល់អត្ថន័យប្រៀបធៀបថា អ្នកទារពន្ធនិងអ្នកបាបសំដៅលើកូនពៅវង្វេងដែលប្រព្រឹត្តតាមចំណង់ប្រាថ្នារបស់ខ្លួន។ ពេលគាត់ស្គាល់ ទុក្ខ វេទនានៃជីវិតកំព្រាគ្មានទីពឹងញ៉ាំងឲ្យគាត់យល់ថា ទង្វើនោះមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់ និងប្រព្រឹត្តអំពើបាបខុសនឹងឪពុក។ គាត់នឹកស្ដាយកំហុស ហើយវិលត្រឡប់មករកឪពុក ដូចអ្នកទារ-ពន្ធ និងអ្នកបាបដែលចូលមកជិតព្រះយេស៊ូ ហើយស្ដាប់ព្រះបន្ទូលព្រះអង្គ។

ចំពោះពួកគណៈផារីស៊ី និងពួកបណ្ឌិតខាងវិន័យ បែរជារអ៊ូរទាំដាក់អ្នកបាបនិងព្រះយេស៊ូដូចកូនច្បង ដែលច្រណែននឹងប្អូន ហើយរអ៊ូរទាំដាក់ឪពុក ដែលមានចិត្តសប្បុរស បណ្ដាលឲ្យខ្លួនឯងនៅខាងក្រៅផ្ទះដាច់ដោយឡែកពីគេតែម្នាក់ឯង។ រីឯបុរសជាឪពុកមានចិត្តអាណិតអាសូរកូន-ពៅក្រៃលែង ហើយគាត់ក៏មិនបដិសេធចំពោះទង្វើល្អរបស់កូនច្បង ដែលជានិមិត្តរូបអំពីព្រះជាម្ចាស់ ដែលមានព្រះហឫ-ទ័យប្រណីសន្ដោសទាំងមនុស្សសុចរិត និងមនុស្សបាប ( លក ១៥,៧.១០ )។

អត្ថបទនេះ បំភ្លឺយើងឲ្យយល់ថា មនុស្សមានសុភមង្គលពិតប្រាកដ ដរាបណាគេទទួលសារភាពអំពើបាប ហើយប្រែចិត្តគំនិត ទទួលយកធម៌មេត្តាករុណារបស់ព្រះជាម្ចាស់មិនមែនពឹងលើខ្លួនឯង ដ្បិតការសង្គ្រោះមកពីព្រះអង្គ។ ផ្ទុយទៅវិញ បើមនុស្សនៅឆ្ងាយពីព្រះជាម្ចាស់ គេហុចឱកាសឲ្យមារល្បួងបណ្ដាលឲ្យខ្លួនធ្លាក់ទៅក្នុង សេចក្ដីទុក្ខ និងភាពឯកា។

**ថ្ងៃអាទិត្យទី៥ រដូវអប់រំពិសេស**
**( យហ ៨,១-១១ )**

អត្ថបទគម្ពីរនេះ ស្ដីពីការជជែកគ្នាយ៉ាងស្រួចស្រាល រវាងការប្រណិប័តន៍តាមធម៌វិន័យ និងការលើកលែងទោស។

ពួកបណ្ឌិតខាងវិន័យ និងពួកខាងគណៈផារីស៊ី ចង់ដាក់អន្ទាក់ព្រះយេស៊ូដោយយក ស្ត្រីប្រព្រឹត្តសហាយស្មន់មកធ្វើជាធ្នាក់ ហើយយកធម្មវិន័យសាសនាយូដា ឬគម្ពីរ "តូរ៉ា" របស់លោកម៉ូសេមកវិនិច្ឆ័យ។ ចំពោះសាសន៍យូដា ការសង្គ្រោះគឺត្រូវកាន់តាមធម្មវិន័យ ដើម្បីគាប់ព្រះហឫទ័យព្រះជាម្ចាស់។ ប្រសិនបើគេប្រព្រឹត្តខុសនឹងធម្មវិន័យ គឺត្រូវមានទោសដល់ស្លាប់ដូចស្ត្រីនោះ។

ព្រះយេស៊ូគូសវាសនៅលើដី ឥតនិ-យាយស្ដី ជាសញ្ញាសម្គាល់ដើម្បីចង្អុលបង្ហាញដើមកំណើតមនុស្សមកពីធូលីដីគឺទន់ទាប។ តែជីវិតមនុស្សមានតម្លៃដោយសារព្រះជាម្ចាស់ បង្កើតគេជារូបតំណាងព្រះអង្គ ហើយចែកព្រះជន្មព្រះអង្គផ្ទាល់ តាមរយៈខ្យល់ដង្ហើមជីវិត។ ដូច្នេះតើត្រូវដាក់ទោសគេដល់ជីវិត ឬត្រូវសង្គ្រោះឲ្យមានជីវិត? ការណ៍នេះ ដាស់សតិសម្បជញ្ញៈរបស់ ពួក គេម្នាក់ ៗ ឲ្យស្គាល់តម្លៃរួមដូចគ្នាថា មនុស្សគ្រប់រូបមានបាប ទោះបីប្រព្រឹត្តតាមធម៌វិន័យក៏មិនបានសុចរិតដែរ ព្រោះវិន័យគ្រាន់តែនាំឲ្យស្គាល់បាប (រម ៣,២០.២៨)។

សេចក្ដីដែលសំខាន់ គឺព្រះហឫទ័យប្រណីសន្ដោស របស់ព្រះជាម្ចាស់ខ្ពង់ខ្ពស់ជាងអំពើបាបរបស់មនុស្ស។ ព្រះជាម្ចាស់សម្ដែងធម៌មេត្តានេះ ឲ្យមនុស្សស្គាល់តាមរយៈព្រះយេស៊ូគ្រីស្ត ដែលលើកលែងទោសឲ្យរួចពីបាប ដូចព្រះអង្គមិនដាក់ទោសស្ត្រីនោះ ហើយចាត់ឲ្យរស់នៅតាមរបៀបថ្មី ដោយមានចិត្តសប្បុរស និងអាណិតមេត្តាគ្នាទៅវិញទៅមក ដូចព្រះ ជាម្ចាស់បាន ប្រណី សន្ដោស យើង ដោយសារព្រះគ្រីស្ត( អភ ៤,៣២ )។

**ថ្ងៃអាទិត្យបុណ្យលើកតម្កើង ព្រះយេស៊ូ សោយទុក្ខលំបាក ( លក ១៩,២៨-៤២ )**

អត្ថបទនេះថ្លែងអំពីធម្មយាត្រារបស់ព្រះយេស៊ូចូលក្រុងយេរ៉ូសាឡឹម ក្នុងនាមជាព្រះមហាក្សត្រពោលគឺព្រះគ្រីស្ត ដែលជនជាតិអ៊ីស្រាអែល ទន្ទឹងរង់ចាំ។ ពីព្រោះរបៀបស្វាគមន៍ និងសម្លេងជយឃោសអបអររបស់ក្រុមសាវ័កបញ្ជាក់ឲ្យស្គាល់ពីឋានៈព្រះអង្គ។ ប៉ុន្តែក្រុមសាវ័កអរសប្បាយ និងលើកតម្កើងព្រះជាម្ចាស់មកពីគេបានឃើញ ព្រះយេស៊ូសម្ដែងបដិហារ ហើយក៏រំពឹងថាព្រះអង្គនឹងធ្វើការអស្ចារ្យជាងនេះ។ ក្រោយមកពួកគេបែរជាអស់សង្ឃឹម នៅពេលឃើញព្រះអង្គសុគតនៅលើឈើឆ្កាងដូចពាក្យខកចិត្តដែលយើងនឹងឮពីសាវ័កពីរនាក់ទៅអេម៉ាអ៊ូស( លក ២៤,១៩-២១ )។

សេចក្ដីនេះដាស់តឿនយើងជាសាវ័កនាសម័យនេះត្រូវជៀសវាង កុំឲ្យប្រទាំថា ជឿលើព្រះយេស៊ូដោយសារព្រះអង្គធ្វើការអស្ចារ្យ ដើម្បីបំពេញតាមកិលេសតណ្ហារបស់ខ្លួន ឬដោយយល់ថាបានជំនួយពីព្រះសហគមន៍ជាដើម។ ផ្ទុយទៅវិញ ត្រូវប្រមើលមើលធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ដែលសម្ដែងឲ្យមនុស្សស្គាល់ ក្នុងអង្គព្រះយេស៊ូគ្រីស្ត ដូចធម្ម-ទេសនារបស់ព្រះអង្គថា "អ្នកណាសោកសៅអ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសម្រាលទុក្ខគេ!"។

ភាពសោកសៅ សំដៅលើធម៌មេត្តាដែលផុសចេញពីជម្រៅនៃដួងចិត្ត ដូចយើងស្ដាប់ឮព្រះយេស៊ូសោកសៅ រហូតទ្រង់ព្រះកន្សែងនឹកអាណិត ក្រុងយេរ៉ូសាឡឹម ជាកន្លែងគេធ្វើគតព្រះអង្គ។ ក្រុងយេរ៉ូសាឡឹម ជាកន្លែងប្រមូលផ្ដុំអំណាចទាំងសាសនា និងនយោបាយ តែពុំយល់ហេតុការណ៍ដែលផ្ដល់សេចក្ដីសុខសាន្ត។ វាជាហេតុនាំឲ្យគេធ្វើគតព្រះយេស៊ូដែលយើងនឹងស្ដាប់ឮនៅក្នុងសប្ដាហ៍ពិសិដ្ឋនេះ។



*លោកកាន់ ប៊ុយ និស្សិតផ្នែកគម្ពីរវិទ្យា*

**ថ្ងៃអាទិត្យ បុណ្យចម្លង ( លក ២៤,១-១២ )**

សេចក្ដីសំខាន់ក្នុងអត្ថបទនេះគឺ "ចូរនឹកចាំព្រះបន្ទូល" ហើយ "រៀបរាប់"។ នឹកចាំព្រះបន្ទូល គឺនឹករឭកអំពីព្រះយេស៊ូ ព្រោះព្រះអង្គជា ព្រះបន្ទូលប្រសូតជាមនុស្ស ( យហ ១,១៤ ) រស់ក្នុងចំណោមសាវ័កដើមដំបូង។ ព្រះអង្គបានរងទុក្ខលំបាក សោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ឬមានព្រះជន្មដ៏រុងរឿង។ សេចក្ដីសង្ឃឹមនៃជំនឿរបស់គ្រីស្ដបរិស័ទគឺចូលរួមក្នុងព្រះជន្មដ៏រុងរឿងនេះ ដ្បិតជាអំណរដ៏ពេញលក្ខណៈ តែត្រូវឆ្លងកាត់ទុក្ខលំបាកដូចព្រះយេស៊ូបានធ្វើជាគំរូសម្រាប់អស់អ្នកដែលព្រះអង្គត្រាស់ហៅ ( ១សិលា ២,២១ )។ ព្រះហឫទ័យរបស់ព្រះជាម្ចាស់ គឺមនុស្សមានសុភមង្គល មិនមែនទុក្ខលំបាកនោះទេ។ តែក៏គ្មាននរណាម្នាក់ទទួលរង្វាន់ដោយមិនឆ្លងកាត់វិញ្ញាសារសាកល្បងនោះដែរបើមិនដូច្នោះទេរង្វាន់នោះគ្មានតម្លៃឡើយ។ រៀបរាប់គឺប្រកាសដំណឹងល្អ និងផ្ដល់សក្ខីភាពនៃជំនឿដល់មនុស្សទាំងឡាយ។ ព្រោះព្រះយេស៊ូផ្ទាល់បានផ្ដល់សក្ខីភាពឲ្យយើងស្គាល់ពីសេច-ក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ និងធ្វើឲ្យជំនឿបានគ្រប់លក្ខណៈ( ហប១២,២ )។ ដូច្នេះ ដល់ពេលព្រះអង្គត្រាស់ហៅយើងឲ្យផ្ដល់សក្ខីភាពអំពីជំនឿនេះហើយ ៕

## កំណាព្យ ក្រមសីលធម៌ពេទ្យនិងភារទទួលខុសត្រូវ

( បទពាក្យ ៧ )



*និពន្ធដោយអ្នកស្រី ខុង ណារី, មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និងសុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្ទួល / JSC*

១- គ្រូពេទ្យជំនាញមានចំណេះ
ជម្ងឺគ្រប់មុខច្រើនខ្លាំងណាស់
ព្យាបាលពិសេសមនុស្សក្មេងចាស់
តែងជួបប្រទះជៀសមិនផុត ។

២- ជួនឈឺតិចតួចស្រាលឬធ្ងន់
ត្រូវកើតគ្រប់ពេលឥតប្រាកដ
រងាក្ដៅគ្រុនគ្មានកំណត់
មិនអាចសន្មត់បញ្ឈប់បាន ។

៣- ឈឺរត់រកពេទ្យទាំងថ្ងៃយប់
ទោះត្រូវចំណាយប្រាក់ប៉ុន្មាន
ជិតឆ្ងាយមិនឈប់ឲ្យតែស្រាន្ត
ប្រឹងប្រែងឲ្យបានដើម្បីជា ។

៤- កន្លែងពេទ្យខ្លះប៉ះអ្នកក្រ
សាកសួររាក់ទាក់មិនធានា
មិនសូវត្រេកអរជម្ងឺគ្នា
រាល់ពេលវេលាបេះតែភ្លេច ។

៥- អ្នកឈឺរមែងតែងរំពឹង
មានតួនាទីភារៈកិច្ច
សង្ឃឹមពំនឹងពេទ្យជានិច្ច
ព្យាបាលច្រើនតិចរៀងរាល់ថ្ងៃ ។

៦- ពេទ្យត្រូវមានក្រមសីលធម៌ល្អ
ដែលមានជីវិតរស់សព្វថ្ងៃ
ដល់អ្នកក្រីក្រផ្ដល់តម្លៃ
រូបយើងគេក្ដីមិនខុសគ្នា ។

៧- ឃើញហើយកន្ដើយធ្វើមិនដឹង
ទុកឲ្យអ្នកឈឺចាប់គ្រាំគ្រា
ឬកពារអស់ហ្នឹងមិនល្អជា
រងទុក្ខវេទនាគ្រាមរណា ។

៨- អ្វីដែលជួយបានសូមលោកជួយ
ផ្ដល់កម្លាំងចិត្តដោយមេត្តា
ប្រជាភ័យព្រួយជួបទុក្ខា
ជួយយកអាសារសង្គ្រោះផង ។

៩- នេះជាបុណ្យមួយដ៏ធំធេង
ជួយជីវិតមនុស្សធំចម្បង
ព្រះបានសម្ដែងថ្លែងកន្លង
ព្រះនឹងតាមស្នងថែរក្សា ។

១០- ធ្វើគុណបានបុណ្យសងជូសវិញ
សាងកុសលល្អក្ដីមេត្តា
ធ្វើបាបពោរពេញជួបឬស្សា
កិត្តិយសថ្លៃថ្លាខ្ពង់ខ្ពស់ឡើង ។

# រូបភាពត្រាស់ហៅបេក្ខជន១០៣រូបនៃព្រះសហគមន៍ភូមិភាគភ្នំពេញ








Radio Veritas Asia
Khmer Service
RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវ៉ារីតាស់អាស៊ីខេមរភាសា

### សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**✤ ផ្សាយតាមរលកធាតុអាកាស FM**

| | | |
|---|---|---|
| ភ្នំពេញ | : FM 104 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : FM 91.0 Mhz | ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : FM 98.75 Mhz | ម៉ោង ៥:០០- ៦:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ |
| កំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

**✤ ផ្សាយតាមរលកធាតុអាកាសខ្លី (SW)**

ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

**✤ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវ៉ារីតាស់អាស៊ី ភាសាខ្មែរ ២៤ ម៉ោង តាមរយៈទូរស័ព្ទ Smart Phone ដែលប្រើប្រព័ន្ធ Android ឬ ប្រព័ន្ធ IOS ដោយគ្រាន់តែចូលទៅកាន់ Play Store ឬ App Store វាយពាក្យ Radio Varitas Asia រួច Download កម្មវិធីនោះដោយស្វែងរកប៊ូតុង (Khmer Live Audio)។




ឬ តាមរយៈវេបសាយ៖ http://khmer.rveritas-asia.org